# ទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)




កម្មវិធីសន្និសីទ | ១៣ - ១៤ កញ្ញា ២០១២

ធ្វើនៅសណ្ឋាគារ **Raffles Le Royal**

សហការរៀបចំដោយៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) និង
គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

## ទិដ្ឋភាពរួម

សន្និសីទស្តីពីទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានគោលបំណងពង្រីកនូវកិច្ចពិភាក្សានៅក្នុងចំណោម មន្ត្រីអ.វ.ត.ក មន្ត្រីរាជរដ្ឋាភិបាល មន្ត្រីតុលាការជាតិ អ្នករៀបចំបង្កើតច្បាប់ អ្នកអនុវត្តច្បាប់ សង្គមស៊ីវិល និងសាធារណជនទូទៅ ដែលពាក់ព័ន្ធនឹងកេរដំណែលរបស់សាលាក្តីកូនកាត់នេះ ក្នុងបរិបទនៃប្រទេសកម្ពុជា ក្នុងតំបន់អាស៊ី ព្រមទាំងច្បាប់អន្តរជាតិ និងគោលនយោបាយ ជាទូទៅ។

## គោលបំណង និងគោលដៅសន្និសីទ

បង្កើតឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើរួចកន្លងមក ក្នុងការរៀបចំកិច្ចពិភាក្សាពីកេរដំណែល និងគម្រោងជាច្រើន ដែលទាក់ទងនឹងកេរដំណែល សន្និសីទនេះ គឺមានបំណងបង្កើនការជជែកពិភាក្សា ដែល កំពុងធ្វើក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗចំពោះបញ្ហាកេរដំណែលនៃ អ.វ.ត.ក។ គោលបំណងនៃសន្និសីទនេះ គឺដើម្បីផ្តល់ជាវេទិកាមួយ ដែលក្នុងនោះ មន្ត្រីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មន្ត្រីរាជរដ្ឋាភិបាល មន្ត្រីតុលាការជាតិ អ្នករៀបចំបង្កើតច្បាប់ អ្នកអនុវត្តច្បាប់ សង្គមស៊ីវិល និងសាធារណជនទូទៅ អាចគិតពិចារណាអំពីកេរដំណែលរបស់ អ.វ.ត.ក ក្នុងកម្រិតជាតិ កម្រិតតំបន់ និងកម្រិតសាកលលោក។

ដោយសារតែដំណើរការជំនុំជម្រះក្តីដោយ អ.វ.ត.ក កាន់តែបោះជំហានទៅមុខ ដូចនេះ បញ្ហា កេរដំណែល គឺជាប្រធានបទដែលមានភាពទាក់ទងដ៏សំខាន់មួយ និងជាផ្នែកនៃយុទ្ធសាស្ត្រនៃកេរដំណែលនៃ សាលាក្តីកូនកាត់មួយនេះ។ ក្នុងចំណោមគោលបំណងជាច្រើន សន្និសីទនេះមានបំណងផ្តួចផ្តើមឲ្យមានការពិភាក្សា និងដំណើរការពិគ្រោះយោបល់ថ្នាក់ជាតិនូវទិដ្ឋភាពនានាជុំវិញបញ្ហាកេរដំណែលរបស់តុលាការ។ ជាងនេះទៀត យើងសង្ឃឹមថា នឹងជម្រុញកិច្ចពិភាក្សាដែលកំពុងបន្តនេះ នូវរបៀបដែលអាចឲ្យយើងទទួលបានចំណេះដឹងដ៏មានប្រសិទ្ធភាពសម្រាប់ផ្ទេរពីតុលាការនេះទៅប្រព័ន្ធតុលាការជាតិ ព្រមទាំងពិភាក្សាទស្សនៈទាន នៃច្បាប់អន្តរជាតិ និងការប្រៀបធៀបស្តីពីយុត្តិសាស្ត្រនៃ អ.វ.ត.ក និងពិចារណាពីមេរៀនបទពិសោធន៍ពី ដំណើរការ អ.វ.ត.ក សម្រាប់តុលាការអន្តរជាតិនានា ផងដែរ។

កេរដំណែល គឺជាពាក្យពេចន៍ដែលមានន័យទូលំទូលាយ នឹងត្រូវការបញ្ជាក់អំពីអត្ថន័យនេះ ឲ្យមាន ភាពជាក់លាក់។ និយមន័យដែលបានប្រើប្រាស់សាមញ្ញបំផុត ដែលកំណត់ដោយការិយាល័យអង្គការសហប្រជាជាតិនៃឧត្តមស្នងការសិទ្ធិមនុស្ស បានកំណត់និយមន័យនៃកេរដំណែល  ថា៖

> “ជាលទ្ធផលយូរអង្វែងរបស់តុលាការកូនកាត់ទៅលើការកសាងនីតិរដ្ឋក្នុងសង្គមមួយជាក់លាក់ ដោយរៀបចំឲ្យមានការកាត់សេចក្តីប្រកបដោយប្រសិទ្ធភាព ឈានទៅបញ្ចប់នូវអំពើនិទណ្ឌភាព, ពង្រឹងសមត្ថភាពស្ថាប័នតុលាការក្នុងស្រុក។ គោលបំណងរបស់កេរដំណែល គឺដើម្បីឲ្យលទ្ធផលនេះបន្តជាប់រហូត សូម្បីតែនៅក្រោយពេលដែលតុលាការកូនកាត់នេះបានបញ្ចប់ការងាររបស់ខ្លួនក៏ដោយ។“
>
> ឧបករណ៍នីតិរដ្ឋសម្រាប់រដ្ឋមានជម្លោះដំបូង,<br>ការបង្កើតឲ្យមានអតិបរមានៃកេរដំណែលរបស់តុលាការកូនកាត់,<br>OHCHR 2008, pp.4-5

តាមរយៈទស្សនៈទាន, ប្រធានបទ និងមេរៀនបទពិសោធន៍ជាច្រើនផ្សេងៗគ្នា បង្ហាញថា នឹងមិនទំនងជាមានកេរដំណែល*តែមួយ*របស់ អ.វ.ត.ក នោះទេ ប៉ុន្តែផ្ទុយមកវិញ គឺមានកេរដំណែលជាច្រើន។ ដោយផ្អែកលើការយល់ដឹងរបស់យើង វាគួរតែយើងនាំគ្នានិយាយថា វាមានកេរដំណែលច្រើនសណ្ឋាន។ កាន់តែច្បាស់លាស់ជាងនេះ គឺថា វាមានវិធីសាស្ត្រជាច្រើន ដែលគេគួរពិភាក្សាអំពីបញ្ហាកេរដំណែល គឺក្នុងក្របខណ្ឌ ក្នុងស្រុក និងក្របខណ្ឌអន្តរជាតិ។ ដោយយោងលើមូលហេតុនេះ សន្និសីទនេះ បែងចែកបញ្ហាកេរដំណែល ជាពីរ (១) កេរដំណែលកម្រិតក្នុងស្រុក និង(២) កេរដំណែលកម្រិតអន្តរជាតិ។ អ.វ.ត.ក អាចមានផ្តល់ផល វិជ្ជមានលើកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ដែលអាចជាប្រភេទមួយនៃកេរដំណែលសម្រាប់តុលាការក្នុងស្រុក។ យុត្តិសាស្ត្រខ្លះនៃ អ.វ.ត.ក ជាយុត្តិសាស្ត្រអន្តរជាតិអាចនឹងបន្សល់ទុកនូវ លទ្ធផលរយៈពេលយូរ ឧទាហរណ៍ ទាក់ទងនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ស្តីពីសហគ្រាសឧក្រិដ្ឋកម្មរួម និងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ មេរៀនបទពិសោធន៍ និងយុត្តិសាស្ត្រ ចេញពីអ.វ.ត.ក អាចចូលរួមចំណែកទៅដល់អភិវឌ្ឍភាព នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ។

នៅក្នុងសន្និសីទនេះ ទស្សនៈចម្រុះនៃកេរដំណែល នឹងត្រូវពិភាក្សាក្នុងចំណោមអ្នកជំនាញនានា។ ទោះបីជាការយកចិត្តទុកដាក់នឹងផ្តោតចំពោះកេរដំណែលផ្នែកច្បាប់ និងផ្នែកយុត្តិសាស្ត្រក្តី សន្និសីទនឹងលើកឡើងផងដែរ អំពីកេរដំណែលក្រៅតុលាការ ដូចជា ការរំលឹកការចងចាំជាដើម។

**ថ្ងៃទី១** — **កេរដំណែលតាមវិស័យផ្សេងៗ**

៧.៣០-៨.១៥ — ការចុះឈ្មោះភ្ញៀវចូលរួម

៨.១៥-៨.២០ — **គោរពភ្លេងជាតិ និងពិធីបើកអង្គសន្និសីទ**

៨.២០ ៩.០០ — **ការណែនាំដោយសង្ខេបអំពីសន្និសីទ**

**ចំណាប់អារម្មណ៍:**

- ឯកឧត្តម **Hady Riad** កុងស៊ុល នៃស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់
- ឯកឧត្តម **Tom Barthel Hansen** ប្រធានស្ថានអគ្គរាជទូតនៃប្រទេសដាណឺម៉ាក (Danida)

សុន្ទរកថា ដោយ ឯកឧត្តមអគ្គរដ្ឋទូត **David Scheffer** អ្នកជំនាញការពិសេសរបស់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ សម្រាប់កម្មវិធីជំនួយរបស់អង្គសហប្រជាជាតិលើការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម (បញ្ចាំងតាម VIDEO)

**សុន្ទរកថាបើកកម្មវិធី:**

- ឯកឧត្តម **ក្រាញ់ តូនី** ប្រធានស្តីទីការិយាល័យរដ្ឋបាល នៃ អ.វ.ត.ក

<u>**កិច្ចពិភាក្សាទី១**</u> — **កេរដំណែលដែលមានលក្ខណៈជាប្រព័ន្ធ - ការទទួលខុសត្រូវ, យុត្តិធម៌ព្រហ្មទណ្ឌ និងកំណែទម្រង់ច្បាប់ - ទស្សនវិស័យផ្សេងៗគ្នា**

**គោលបំណង និងទិសដៅនៃសន្និសីទ**

- លោក **Simon Meisengberg** ទីប្រឹក្សាផ្នែកច្បាប់នៃ CIM/ECCC

៩.០០-៩.៥០ — **ប្រធានក្រុមពិភាក្សា:** លោកចៅក្រម **Rowan Downing** ចៅក្រមអង្គបុរេជំនុំជម្រះ នៃ អ.វ.ត.ក

<u>**វាគ្មិន:**</u>

- ឯកឧត្តម **Stephen Rapp** ឯកអគ្គរដ្ឋទូតគោចរ នៃការិយាល័យ យុត្តិធម៌ព្រហ្មទណ្ឌសកលនៃក្រសួងការបរទេសសហរដ្ឋអាមេរិក និងជាអតីតអគ្គរដ្ឋអាជ្ញានៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បង្ហាញអំពី *"ទស្សនៈទានអន្តរជាតិលើកេរដំណែលនៃអ.វ.ត.ក"*
- ឯកឧត្តម **ស៊ុយ ម៉ុងលាង** អគ្គលេខាធិការនៃលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បង្ហាញអំពី *"ទស្សនៈទានកម្រិតជាតិទៅលើកេរដំណែល នៃ អ.វ.ត.ក"*
- លោក **Andrew Cayley** ជាសហព្រះរាជអាជ្ញាអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បង្ហាញអំពី *"កេរដំណែលផ្នែកការកាត់ទោសរបស់ អ.វ.ត.ក"*
- លោក **James Heenan** អ្នកតំណាងស្តីទី នៃការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា បង្ហាញអំពី *"អាណត្តិរបស់ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងគោលនយោបាយរបស់អង្គការសហប្រជាជាតិស្តីពីបញ្ហាកេរដំណែល"*
- លោកស្រីបណ្ឌិត **ហៅឡេន ចារីស** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា បង្ហាញពី *"តើចំណាយពេលយូរប៉ុណ្ណា ទម្រាំក្តីរំពឹងទុកក្លាយជាការពិត៖ បទពិសោធន៍នៃអ.វ.ត.ក"*

៩.៥០-១០.២០ — សំណួរ និងចម្លើយ នៃកិច្ចពិភាក្សាក្រុមទី១

១០.២០-១០.៤០ — សម្រាកអាហារសម្រន់

**<u>កិច្ចពិភាក្សាទី២:</u>** **ប្រៀបធៀបកេរដំណែល - កេរដំណែល នៃតុលាការព្រហ្មទណ្ឌ (ដែលមានលក្ខណៈ) អន្តរជាតិផ្សេងៗ**

១០.៤០-១១.៣០: **ប្រធានក្រុមពិភាក្សា:** លោកស្រីចៅក្រម **Agnieszka Klonowiecka-Milart** ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក

**<u>វាគ្មិន:</u>**

- លោកស្រី **Viviane Dittrich** បេក្ខជនបណ្ឌិតនៅសាលាសេដ្ឋកិច្ច នៃទីក្រុង London បង្ហាញអំពី *"កេរដំណែល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ: ទិដ្ឋភាពរួមនៃគំនិត"*
- លោកស្រីចៅក្រម **Renate Winter** ចៅក្រមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន បង្ហាញពី *"កេរដំណែលនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន"*
- លោកបណ្ឌិត **Ousman Njikam** មន្ត្រីច្បាប់ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បង្ហាញអំពី *"កេរដំណែល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី"*
- លោកស្រី **Caitlin Reiger** អតីតនាយិកាកិច្ចការទំនាក់ទំនងនយោបាយអន្តរជាតិ នៃមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល បង្ហាញអំពី *"កេរដំណែល នៃតុលាការពិសេសនៅប្រទេសទីម័រខាងកើត"*

១១.៣០-១២.០០: សំណួរ និងចម្លើយនៃកិច្ចពិភាក្សាទី២

១២.០០-១៣.៣០: សម្រាកពិសាអាហារថ្ងៃត្រង់

**<u>កិច្ចពិភាក្សាទី៣:</u>** **កេរដំណែលផ្នែកយុត្តិសាស្ត្រ**

១៣.៣០-១៤.៤៥: **ប្រធានក្រុមពិភាក្សា:** ឯកឧត្តម **គង់ ស្រ៊ីម** ប្រធានអង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក

**<u>វាគ្មិន:</u>**

- លោកសាស្ត្រាចារ្យ **Nina Jorgensen** ជំនួយការសាស្ត្រាចារ្យនៅសកលវិទ្យាល័យចិន នៃទីក្រុងហុងកុង បង្ហាញអំពី *"កេរដំណែលផ្នែកយុត្តិសាស្ត្ររបស់ អ.វ.ត.ក អំពីទម្រង់នៃការទទួលខុសត្រូវ"*
- ឯកឧត្តម **យូ ប៊ុនឡេង** សហចៅក្រមស៊ើបអង្កេត នៃ អ.វ.ត.ក បង្ហាញអំពី *"កេរដំណែលផ្នែកនីតិវិធីរបស់ អ.វ.ត.ក"*
- លោកមេធាវី **Michael karnavas** សហមេធាវីអន្តរជាតិការពារក្តី នៅ អ.វ.ត.ក បង្ហាញអំពី *"ការធ្វើឲ្យសំណុំរឿងក្នុងស្រុកមានលក្ខណៈអន្តរជាតិ - ការអនុវត្តសំណុំរឿងរបស់អ.វ.ត.ក នៅកម្រិតជាតិ"*
- លោកស្រី **Anne Heindel** ទីប្រឹក្សាច្បាប់ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញអំពី *"ការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក និងមេរៀនសម្រាប់ការជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត"*
- បណ្ឌិត **Binxin Zhang** អ្នកស្រាវជ្រាវ នៅសាកលវិទ្យាល័យស៊ាម៉េន បង្ហាញអំពី *"បទពិសោធន៍ចេញពីការពិនិត្យប្រៀបធៀបនៃក្របខ័ណ្ឌការចូលរួមរបស់ជនរងគ្រោះចំពោះមុខ អ.វ.ត.ក និងតុលាការព្រហ្មទណ្ឌអន្តរជាតិ"*

១៤.៤៥-១៥.១៥: សំណួរ និងចម្លើយ នៃកិច្ចពិភាក្សាទី៣

១៥.១៥-១៥.៣០: សម្រាកអាហារសម្រន់

**<u>កិច្ចពិភាក្សាទី៤:</u>** **កេរដំណែលក្រៅតុលាការ** *

១៥.៣០-១៦.៤៥: **ប្រធានក្រុមពិភាក្សា:** លោកចៅក្រម **ម៉ុង មុន្នីចរិយា** ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក

**<u>វាគ្មិន:</u>**

- លោកសាស្ត្រាចារ្យ **David Cohen** សាស្ត្រាចារ្យនៅសកលវិទ្យាល័យកាលីហ្វ័រនី បឺឃ្លេ បង្ហាញអំពី *"កេរដំណែលប្រវត្តិសាស្ត្រដែលជាប្រវត្តិសាស្ត្ររស់រវើក: ការចងក្រងការងារនៃតុលាការឧក្រិដ្ឋកម្មសង្គ្រាមក្នុងសម័យកាលជាក់ស្តែងមួយ"*
- លោក **តាន់ វិសាល** អ្នកគ្រប់គ្រងគម្រោងវិធានការមិនមែនតុលាការនៃអង្គភាពគាំពារជនរងគ្រោះ បង្ហាញអំពី *"ធ្វើឲ្យវិធានការមិនមែនតុលាការនៅក្នុងអាណត្តិអ.វ.ត.ក ក្លាយជាការពិតជាក់ស្តែង"*
- លោកស្រី **Theresa de Langis** អ្នកឯកទេសជាន់ខ្ពស់ផ្នែកសិទ្ធិស្ត្រី *"ការនិទានផ្សេង/ ឧក្រិដ្ឋកម្មដែលស្ងៀមស្ងាត់៖ ការថ្លែងពីបទពិសោធន៍របស់ស្ត្រីក្នុងរបបខ្មែរក្រហម"*
- លោក **David Taylor** អ្នកស្រាវជ្រាវ និងទីប្រឹក្សាគោលនយោបាយនៃអង្គការឃ្លាំមើលនិទណ្ឌភាព បង្ហាញអំពី *"កេរដំណែលនៅក្រៅបន្ទប់សវនាការ៖ ទំនាក់ទំនងរវាងពិធីរំលឹកការចងចាំនិងយុត្តិធម៌ព្រហ្មទណ្ឌ"*
- លោកវេជ្ជបណ្ឌិត **ឈឹម សុធារ៉ា** នាយកអង្គការចិត្តសង្គមអន្តរវប្បធម៌ បង្ហាញអំពី *"ការដោះស្រាយជាមួយអតីតកាលតាមទស្សនទានផ្នែកចិត្តវិទ្យា"*
- លោកមេធាវី **សូ មូស្សេរ៉ុន្នី** បង្ហាញអំពី *"ការគ្រប់គ្រងសំណុំរឿងតាមទស្សនទានមេធាវីការពារក្តី: បញ្ហាប្រឈម និងឱកាស "*

១៦.៤៥-១៧.១៥: សំណួរ និងចម្លើយ នៃក្រុមពិភាក្សាទី៤

១៧.៣០: **បដិសណ្ឋារកិច្ច** (**ការអញ្ជើញដោយឡែកសម្រាប់អ្នកត្រូវអញ្ជើញជាក់លាក់ប៉ុណ្ណោះ**)
សុន្ទរកថាស្វាគមន៍
លោក **ធន សារាយ** ប្រធានសម្របសម្រួលគណៈកម្មាធិការប្រព្រឹត្តិកម្ម
*សម្ពោធ ឯកសារស្តីពីឧបករណ៍គោលនយោបាយកេរដំណែល*
លោក **James Heenan** អ្នកតំណាងស្តីទី នៃការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា

* ក្នុងកិច្ចពិភាក្សាចុងក្រោយនេះ ប្រធានបទនានានឹងត្រូវបានបង្ហាញឡើងថា នឹងត្រូវបានពិនិត្យពិច័យបន្ថែមនៅក្នុងវេទិកាផ្លាស់ប្តូរគំនិតផ្តួចផ្តើមការចងចាំអន្តរជាតិមួយដែលត្រូវបានរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅណឺដឺឡែន អង្គការ Impunity Watch ជាមួយអង្គការដៃគូកម្ពុជា ដែលនឹងប្រារព្ធធ្វើនៅទីក្រុងភ្នំពេញបន្ទាប់ពីសិក្ខាសាលាកេរដំណែល។ វេទិកាផ្លាស់ប្តូរ នឹងនិយាយលម្អិតអំពីកេរដំណែលមិនមែនតុលាការ ជាពិសេសភាពទំនាក់ទំនងរវាងយុត្តិធម៌ព្រហ្មទណ្ឌ និងពិធីរំលឹកការចងចាំ។

**ថ្ងៃទី២: កិច្ចពិភាក្សាក្រុមការងារ និងការបង្ហាញអនុសាសន៍ចំពោះតួអង្គសំខាន់ៗស្តីពីកេរដំណែល**

__គោលបំណង:__ ក្រុមការងារ នឹងត្រូវប្រជុំគ្នាពិភាក្សាជុំវិញប្រធានបទនានានៃកិច្ចពិភាក្សា ហើយការពិភាក្សាដែលបាន បំបែកនឹងត្រូវធ្វើឡើងនៅពេលព្រឹក ដោយសំលឹងមើលយ៉ាងជាក់លាក់លើបញ្ហាដែលបានលើកយកមកពីកិច្ចពិភាក្សានានា និងការដាក់សំណួរបន្ថែមទៀត។ កិច្ចការរបស់ក្រុមការងារនានា គឺនឹងពិចារណាពីបរិបទសកលនៃបញ្ហានានា ដែលបានពិភាក្សា ហើយនឹងបង្កើត "ជំហានបន្ត" និងអនុសាសន៍នានាសម្រាប់ដំណើរការ នៃការធានាថា បច្ចុប្បន្នសកម្មភាពយុត្តិធម៌អន្តរកាលកំពុងដំណើរការក្នុងប្រទេសកម្ពុជា (ជាពិសេស គឺការងារនៃ អ.វ.ត.ក) ទទួលបាននូវលទ្ធផលជាអតិបរមា។ អ្នកជំនាញនានា នឹងត្រូវហៅមកសួរ/បញ្ជាក់ចំពោះសំណួរ ដែលបានសួរដោយក្រុមនីមួយៗ។ ក្រុមនីមួយៗ នឹងមានអ្នកចូលរួមប្រហែល ៣០នាក់។ ក្រុមនីមួយៗ នឹងដឹកនាំដោយអ្នកសម្របសម្រួលម្នាក់ (ឬសហអ្នកសម្របសម្រួល) ដែលត្រូវបានកំណត់ឡើងមុនពេលសិក្ខាសាលា។ អ្នកសម្រួលសម្រួល គឺទទួលខុសត្រូវចំពោះ (១) ការរៀបចំក្រុមការងារ (២)ការសម្របសម្រួល (៣)ការកត់កំណត់ហេតុ/អនុសាសន៍។ អ្នកសម្របសម្រួល នឹងត្រូវផ្តល់ជូននូវគោលណែនាំ និងទម្រង់គំរូមួយដោយអ្នករៀបចំសិក្ខាសាលា។

ក្រុមការងារនីមួយៗ នឹងចាត់តាំងអ្នករាយការណ៍ម្នាក់ក្នុងចំណោមសមាជិកក្រុមពិភាក្សា ដែលនឹងរាយការណ៍ពីលទ្ធផលនៃការពិភាក្សានៅក្នុងអង្គសិក្ខាទាំងមូលនៅពេលរសៀល។ ក្រុមការងារ នឹងចាប់ផ្តើមជាមួយនឹងសុន្ទរកថាចំណាប់អារម្មណ៍ដោយវាគ្មិនមួយចំនួនមុនពេលដំណើរការពិភាក្សា។ នៅថ្ងៃចុងបញ្ចប់នៃសិក្ខាសាលា ក្រុមអ្នកជំនាញនឹងត្រូវប្រជុំគ្នាដោយការបញ្ចូលអ្នករាយការណ៍ (៦នាក់) និងអ្នកជំនាញ (៦នាក់) ដើម្បីបង្កើតជាអនុសាសន៍សំខាន់ៗដោយផ្អែកលើការពិភាក្សា។

__**បែបបទនឹងដំណើរការដូចខាងក្រោម:**__

| | |
|---|---|
| ៨.១៥-៩.១៥: | ចំណាប់អារម្មណ៍របស់វាគ្មិន |
| ៩.១៥-១០.១៥: | កិច្ចពិភាក្សាស្តីពី "ជំហានបន្ទាប់" /គម្រោងសម្រាប់អនាគត |
| ១០.១៥-១០.៣០: | សម្រាកអាហារសម្រន់ |
| ១០.៣០-១២.០០: | អនុសាសន៍ |
| ៨.០០-៨.១៥: | ការប្រកាសជូនដំណឹងអំពីក្រុមការងារ |

៨.១៥-១២.០០: **ក្រុមទី១: __ក្រុមការងារផ្នែកតុលាការ__**

**ក្រុមទី១(ក): កេរដំណែលផ្នែកយុត្តិសាស្ត្រ នៃ អ.វ.ត.ក**
អ្នកសម្របសម្រួលៈ លោកចៅក្រម **ហួត វុទ្ធី** ចៅក្រមអង្គបុរេជំនុំជម្រះ នៃ អ.វ.ត.ក

**__វាគ្មិនទី១:__** លោកចៅក្រម **ស៊ិន រិទ្ធ** ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក បង្ហាញអំពី "*យុត្តិសាស្ត្រនៃអ.វ.ត.ក តាមទស្សនទានជាតិ*"

**__វាគ្មិនទី២:__** លោកចៅក្រម Chang-Ho Chung ចៅក្រមអង្គបុរេជំនុំជម្រះ នៃ អ.វ.ត.ក បង្ហាញពី "*យុត្តិសាស្ត្រជាលក្ខណៈអន្តរជាតិនៅ អ.វ.ត.ក*"

**__វាគ្មិនទី៣:__** លោក **អាង ឧត្តម** សហមេធាវីការពារក្តីនៅ អ.វ.ត.ក បង្ហាញអំពី "*យុត្តិសាស្ត្រជាបទពិសោធន៍ជាក្នុងនាមជាមេធាវីការពារក្តីនៅ អ.វ.ត.ក*"

**__វាគ្មិនទី៤:__** លោក **សុក សំអឿន** នាយកប្រតិបត្តិ នៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បង្ហាញអំពី "*ជំនួយផ្នែកច្បាប់នៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក*"

**<u>វាគ្មិនទី៥:</u>** លោក **សួន វិសាល** អគ្គលេខាធិការ នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា *"ប្រែក្លាយកេរដំណែលផ្នែកយុត្តិសាស្ត្ររបស់អ.វ.ត.ក ឲ្យទៅជាការអនុវត្តជាក់ស្តែង"*

**ក្រុមទី១(ខ): កេរដំណែលផ្នែកយុត្តិសាស្ត្រនៃ អ.វ.ត.ក ក្នុងបរិបទនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី**

<u>អ្នកសម្របសម្រួល:</u> លោក **សួន ប៊ុនស័ក្តិ** លេខាធិការប្រតិបត្តិនៃគណៈកម្មាធិការប្រព្រឹត្តិកម្ម

**<u>វាគ្មិនទី១:</u>** លោក **ពេជ អង្គ** សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញអំពី *"ទិដ្ឋភាពកេរដំណែលផ្នែកយុត្តិសាស្ត្រទាក់ទងនឹងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រព័ន្ធច្បាប់កម្ពុជា"*

**<u>វាគ្មិនទី២:</u>** លោកស្រី **Elisabeth Simmoneau Fort** សហមេធាវីនាំមុខអន្តរជាតិតំណាង ដើមបណ្តឹងរដ្ឋវេណី បង្ហាញអំពី *"ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតាមទស្សនទានអន្តរជាតិ"*

**<u>វាគ្មិនទី៣:</u>** លោកស្រី **ទី ស្រ៊ីនណា** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញអំពី *"ការតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខ អ.វ.ត.ក"*

**<u>វាគ្មិនទី៤:</u>** លោក **ហុង គឹមសួន** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញអំពី *"បទពិសោធន៍ពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការអនុវត្តជាក់ស្តែង"*

**ក្រុមទី២: បទពិសោធន៍ចេញពីការឃ្លាំមើលតុលាការ**

<u>អ្នកសម្របសម្រួល:</u> លោក ស្រី **Kris Baleva** នាយកកម្មវិធី AIJI Cambodia

**<u>វាគ្មិនទី១:</u>** លោកស្រី **Clair Duffy** អ្នកឃ្លាំមើលតុលាការ នៃអង្គការ OSJI បង្ហាញអំពី *"ការឃ្លាំមើល អ.វ.ត.ក ជាស្ថាប័នមួយ"*

**<u>វាគ្មិនទី២:</u>** លោក **Florian Hansen** អ្នកសម្របសម្រួលកម្មវិធីឃ្លាំមើល នៅសកលវិទ្យាល័យ Marburg បង្ហាញអំពី *"ការបង្កើតនូវកម្មវិធីឃ្លាំមើលតុលាការ, ជោគជ័យ និងការលំបាក"*

**<u>វាគ្មិនទី៣:</u>** លោក **អ៊ូ វីរៈ** ប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្ហាញអំពី *"ដំណើរការឃ្លាំមើលតុលាការក្នុងស្រុក និងអត្ថប្រយោជន៍របស់វា"*

**<u>វាគ្មិនទី៤:</u>** លោកបណ្ឌិត **ឡៅ ម៉ុងហៃ** អ្នកវិភាគឯករាជ្យ និងអតីតអ្នកស្រាវជ្រាវជាន់ខ្ពស់ នៅគណៈកម្មការសិទ្ធិមនុស្សអាស៊ី បង្ហាញអំពី *"បទពិសោធន៍សំខាន់ៗចេញពីការឃ្លាំមើលដំណើរការ អ.វ.ត.ក"*

**ក្រុមទី៣: សកម្មភាពផ្សព្វផ្សាយ និង ការធ្វើបណ្ណសារ និងចងក្រងឯកសារការងាររបស់ អ.វ.ត.ក**

<u>អ្នកសម្របសម្រួល:</u> លោក **ចោង សុជាតិ** ប្រធានលេខាធិការដ្ឋានកេរដំណែលរបស់ អ.វ.ត.ក

**<u>វាគ្មិនទី១:</u>** លោក **ឌឹម សុវណ្ណារុំ** ប្រធានផ្នែកកិច្ចការសាធារណៈ នៃ អ.វ.ត.ក បង្ហាញអំពី *"សកម្មភាពផ្សព្វផ្សាយរបស់អ.វ.ត.ក - ការបន្សល់ទុកនូវកេរដំណែល "*

**វាគ្មិនទី២:** លោក **អ៊ឹង ហឿឌី** មន្ត្រីកម្មវិធី នៃគណៈកម្មាធិការប្រព្រឹត្តិកម្ម បង្ហាញអំពី *"តួនាទីរបស់សង្គមស៊ីវិលក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី - ការរីកចំរើនឆ្ពោះទៅការចូលរួមរបស់ជនរងគ្រោះ"*

**វាគ្មិនទី៣:** លោក **ឡាត់ គី** អ្នកសម្របសម្រួលកម្មវិធីតុលាការខ្មែរក្រហម នៃសមាគមអាដហុក បង្ហាញអំពី "សកម្មភាពផ្សព្វផ្សាយនៃតួអង្គសង្គមស៊ីវិលពាក់ព័ន្ធនឹង អ.វ.ត.ក"

**វាគ្មិនទី៤:** លោក **ហាស ប៊ុនថន** អនុប្រធានផ្នែក ICT បង្ហាញពី *"តុលាការទូរនិម្មិតនៅ អ.វ.ត.ក: បទពិសោធន៍ប្រព័ន្ធឌីជីថលសម្រាប់តុលាការក្នុងស្រុក"*

**ក្រុមទី៤: កេរដំណែលខាងចិត្តវិទ្យា: ការគាំពារសាក្សី និងការវាយតម្លៃខាងចិត្តវិទ្យា**

អ្នកសម្របសម្រួល: លោកវេជ្ជបណ្ឌិត **មុន្នី សុត្ថារា** អ្នកចិត្តវិទ្យា នៃអង្គការចិត្តសង្គម អន្តរវប្បធម៌ / កញ្ញា **Judith Strasser** ទីប្រឹក្សា GIZ ប្រចាំអង្គការចិត្តសង្គម អន្តរវប្បធម៌

**វាគ្មិនទី១:** លោកស្រី **Wendy Lobwein** ប្រធានអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នៃ អ.វ.ត.ក បង្ហាញពី *"បទពិសោធន៍នៃការគាំពារសាក្សីនៅ អ.វ.ត.ក"*

**វាគ្មិនទី២:** លោកស្រី **សេក ស៊ីសុខុម** ប្រធានដេប៉ាត់ម៉ង់ចិត្តវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បង្ហាញអំពី *"ការវាយតម្លៃខាងចិត្តវិទ្យា និងការទទួលខុសត្រូវព្រហ្មទណ្ឌ"*

**វាគ្មិនទី៣:** លោកវេជ្ជបណ្ឌិត **Steen-Holger Hansen** អនុប្រធានផ្នែកកោសលវិច្ឆ័យចិត្តសាស្ត្រ នៃសាកលវិទ្យាល័យ Copenhagen, ក្រុមប្រឹក្សាស្តារនីតិសម្បទាអន្តរជាតិសម្រាប់ជនរងគ្រោះដោយសារទារុណកម្ម (IRCT) បង្ហាញអំពី *"ការប្រើប្រាស់ការពិនិត្យកោសលវិច្ឆ័យនៅក្នុងនីតិវិធី តុលាការ៖ មេរៀនពី អ.វ.ត.ក"*

**ក្រុមទី៥: កេរដំណែលនៃ អ.វ.ត.ក ស្តីពីការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី**

អ្នកសម្របសម្រួល: លោក **អ៊ីម សុភា** ប្រធានកម្មវិធីផ្សព្វផ្សាយ នៃអង្គភាពគាំពារជនរងគ្រោះ នៃអ.វ.ត.ក

**វាគ្មិនទី១:** លោក **ដួង សាវន** អ្នកសម្របសម្រួលគម្រោង នៃក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា បង្ហាញអំពី *"បញ្ហារំលោភយេនឌ័រនៅក្នុងបរិបទនៃ អ.វ.ត.ក"*

**វាគ្មិនទី២:** លោកបណ្ឌិត **Andreas Selmici** អ្នកគ្រប់គ្រងគម្រោង "ការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី" នៃអង្គការ GIZ ប្រចាំកម្ពុជា បង្ហាញអំពី *"យុត្តិធម៌ផ្នែកយេនឌ័រ: ការប្រមើលមើល និងបញ្ហាប្រឈម"*

**វាគ្មិនទី៣:** លោកស្រី **លី វិផ្មតា** នាយិកាប្រតិបត្តិ នៃអង្គការជំនួយផ្នែកច្បាប់ដល់កុមារ និងស្ត្រី បង្ហាញអំពី *"ការអនុវត្តយុត្តិធម៌ផ្នែកយេនឌ័រនៅក្នុងប្រព័ន្ធថ្នាក់ជាតិ"*

១២.០០-១៣.៣០: សម្រាកអាហារថ្ងៃត្រង់

**កិច្ចពិភាក្សាក្នុងអង្គសន្និសីទរួម**

១៣.៣០-១៤.៣០: **កិច្ចពិភាក្សាអង្គសន្និសីទរបស់ក្រុមការងារ ១(ក) - ១(ខ), ៣**

សហអ្នកសម្របសម្រួល: លោក **គង់ សុភី** ប្រធានផ្នែកគ្រប់គ្រងតុលាការ នៃអ.វ.ត.ក / លោក **Simon Meisenberg** ទីប្រឹក្សា ICM/ECCC

អ្នករាយការណ៍ ធ្វើសេចក្តីរាយការណ៍ត្រឡប់ចេញពីកិច្ចពិភាក្សាកាលពីពេលព្រឹក (១០នាទីសម្រាប់ក្រុមពិភាក្សានីមួយ)
*សំណួរ និងចម្លើយ ពីអ្នកជំនាញ និងអ្នកចូលរួម (រយៈពេល ៣០នាទី)*

១៤.៣០-១៥.៣០: **កិច្ចពិភាក្សាអង្គសន្និសីទរបស់ក្រុមការងារ ២, ៤, ៥**
សហអ្នកសម្របសម្រួលៈ លោកបណ្ឌិត **Ignaz Stegmiller** ជាទីប្រឹក្សា GIZ/CPS ប្រចាំគណៈ កម្មាធិការប្រព្រឹត្តិកម្ម / លោកស្រីបណ្ឌិត **Laura McGrew** ទស្សនៈកិច្ចវិទូរ នៃមជ្ឈមណ្ឌល សម្រាប់សិក្សានៃអំពើប្រល័យពូជសាសន៍ដំណោះស្រាយជម្លោះនិងសិទ្ធិមនុស្ស សាកលវិទ្យាល័យ Rutgers

អ្នករាយការណ៍ ធ្វើសេចក្តីរាយការណ៍ត្រឡប់ចេញពីកិច្ចពិភាក្សាកាលពីពេលព្រឹក (១០នាទីសម្រាប់ក្រុមនីមួយ)
*សំណួរ និងចម្លើយ ពីអ្នកជំនាញ និងអ្នកចូលរួម (រយៈពេល ៣០នាទី)*

១៥.៣០-១៦.០០: សម្រាកអាហារសម្រន់

១៦.០០-១៧.០០: **ការបង្កើត និងការបង្ហាញអំពីអនុសាសន៍រួម និងបិទកម្មវិធីសន្និសីទ**
លោក **គង់ សុភី** ប្រធានផ្នែកគ្រប់គ្រងតុលាការ នៃអ.វ.ត.ក / លោក **Simon Meisenberg** ទីប្រឹក្សា ICM/ECCC

លោកបណ្ឌិត **Ignaz Stegmiller** ជាទីប្រឹក្សា GIZ/CPS ប្រចាំគណៈ កម្មាធិការប្រព្រឹត្តិកម្ម / លោកស្រីបណ្ឌិត **Laura McGrew** ទស្សនៈកិច្ចវិទូរ នៃមជ្ឈមណ្ឌលសម្រាប់សិក្សានៃអំពើប្រល័យ ពូជសាសន៍ដំណោះស្រាយជម្លោះនិងសិទ្ធិមនុស្ស សាកលវិទ្យាល័យ Rutgers
*គណៈវាគ្មិននឹងបង្ហាញនូវអនុសាសន៍ និងចូលរួមនៅក្នុងកិច្ចពិភាក្សាចុងក្រោយ, កិច្ចពិភាក្សាសង្ខេប។ អនុសាសន៍ចុងក្រោយនឹងទាក់ទងនឹង អ.វ.ត.ក, ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងអ្នកចូលរួមពាក់ព័ន្ធដទៃទៀត។*

លោក **រោង ឈង** មន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងជាប្រធានផ្នែកគាំពារជនរងគ្រោះនៃអ.វ.ត.ក មានមតិទៅលើលទ្ធផលរួមនៃអង្គសន្និសីទ

**សុន្ទរកថាបិទកម្មវិធី** ដោយ លោក **ធន សារាយ** ប្រធានសម្របសម្រួលនៃគណៈកម្មាធិការប្រព្រឹត្តិកម្ម និងជាប្រធានសមាគម អាដហុក

*<u>សំគាល់៖</u> សហអ្នករៀបចំសូមសិទ្ធិកែប្រែកម្មវិធី ប្រសិនបើចាំបាច់។*

## ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**លោក អាង ឧត្តម** សហមេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចាប់តាំងពីឆ្នាំ២០០៧។ លោកមានបទពិសោធន៍ជាច្រើនក្នុងការងារការពារក្តីនៅក្នុងប្រទេសកម្ពុជា។ នៅមុនពេលតែងតាំងជាសហមេធាវីជាតិការពារក្តីនៅអ.វ.ត.ក លោកធ្លាប់ជាមេធាវីការពាររឿក្តីព្រហ្មទណ្ឌ នៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា និងធ្លាប់ជាប្រធានអង្គភាពច្បាប់នៃមជ្ឍមណ្ឌលអភិវឌ្ឍន៍សង្គម។ លោកបានក្លាយជាសមាជិកគណៈមេធាវីកម្ពុជាតាំងពីឆ្នាំ១៩៩៧ និងបានបង្កើតនិងគ្រប់គ្រងការិយាល័មេធាវីផ្ទាល់ខ្លួន ចាប់តាំងពីឆ្នាំ១៩៩៩ មក។

**កញ្ញា BALEVA Mary Kristerie** គឺជាមេធាវីសញ្ជាតិហ្វីលីពីនកំពុងបំរើការងារជាប្រធានកម្មវិធីរបស់អង្គការ AIJI ប្រចាំកម្ពុជា។ កញ្ញាគឺជាអ្នកគ្រប់គ្រងកម្មវិធីឃ្លាំមើលការជំនុំជម្រះក្តីនៃសាលាក្តីខ្មែរក្រហម និងផ្សព្វផ្សាយសហគមន៍ ព្រមទាំងក្រុមអ្នកច្បាប់ដែលចូលរួមជួយរៀបចំខ្លឹមសារនៃតុលាការទូរនិម្មិតរបស់សាលាក្តីខ្មែរក្រហម ដែលជាគំរោងសហការរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាមួយនឹងអង្គការ EWC អង្គការ WCSC និងវិទ្យាស្ថាន Hoover នៃសាកលវិទ្យាល័យ Standfort។ កញ្ញា **គ្រីស្ត** បានសិក្សានៅសាកលវិទ្យាល័យហ្វីលីពីនជាកន្លែងដែលកញ្ញាទទួលបានមេដាយសម្រាប់អ្នករៀនពូកែពីព្រឹទ្ធបុរសសាកលវិទ្យាល័យ។ ក្នុងឆ្នាំ២០០៩ កញ្ញាទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសិទ្ធិមនុស្សពីសាកលវិទ្យាល័យហុងកុង។ មុនពេលកញ្ញាចូលរួមក្នុងគម្រោងនេះ កញ្ញាបានបំរើការងារជានាយិកាសម្រាប់កិច្ចការនីតិកម្មនៅក្នុងព្រឹទ្ធសភា ហ្វីលីពីន និងជាមេធាវីនៅការិយាល័យមេធាវី SyCip Salazar Hernandez Gatmaitan។

**លោក ហាស ប៊ុនថន** បានចូលបំរើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងដើមខែធ្នូ ឆ្នាំ២០០៩ ជាអនុប្រធានផ្នែកបច្ចេកវិជ្ជាព័ត៌មាន និងទំនាក់ទំនង (ICT) សម្រាប់ការិយាល័យរដ្ឋបាលតុលាការ។ មុនការចូលបំរើការនៅ អ.វ.ត.ក លោកបានបំរើការនៅសាកលវិទ្យាល័យន័រតុនជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិទ្យាសាស្ត្រអស់រយៈពេល ៩ឆ្នាំ។ លោកក៏បានបំរើការជាប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងការស្ទង់មតិ និងជាអគ្គនាយក រងទទួលបន្ទុកបច្ចេកវិជ្ជាព័ត៌មាន និងទំនាក់ទំនងនៃវិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ។ លោកធ្លាប់បំរើការនៅវិទ្យាស្ថានជាតិស្ថិតិ ចាប់ពីឆ្នាំ១៩៩១។ លោក ប៊ុនថន មានសញ្ញាប័ត្រអនុបណ្ឌិតចំនួនពីរ គឺសញ្ញាប័ត្រ អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្របច្ចេកវិជ្ជានៅសាកលវិទ្យាល័យ De La Salle ក្រុងម៉ានីល ប្រទេសហ្វីលីពីន និងសញ្ញាប័ត្រអនុបណ្ឌិតផ្នែកស្ថិតិ នៅសាកលវិទ្យាល័យ Polytechnic ប្រទេសហ្វីលីពីន ព្រមទាំងមានសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថានសេដ្ឋកិច្ច រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**លោក ANDREW Cayley, QC**, ត្រូវបានតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចាប់ពីខែធ្នូ ឆ្នាំ២០០៩។ នៅមុននេះ លោកគឺជារដ្ឋអាជ្ញាជាន់ខ្ពស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ និងបានទទួលបន្ទុករឿងក្តីដាហ្វួ (Darfur) ដំបូង។ លោកក៏ធ្លាប់បានបម្រើការជារដ្ឋអាជ្ញា បន្ទាប់មកជា  រដ្ឋអាជ្ញាជាន់ខ្ពស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយ៉ូហ្គោស្លាវី។ លោកជាមេធាវីជាន់ខ្ពស់មួយរូបនៃគណៈមេធាវី Inner Temple និងមានបរិញ្ញាប័ត្រ និងសញ្ញាប័ត្រអនុបណ្ឌិតផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យឡុងដ៍។ លោកក៏ជាមន្ត្រីជំនាញមួយរូបដែលបានបញ្ចប់ការសិក្សាពីរាជបណ្ឌិតសភាយោធា Sandhurst នៃចក្រភពអង់គ្លេសផងដែរ។

**លោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា** គឺជាអ្នកជំនាញខាងផ្នែកចិត្តវិកល និងនាយកប្រតិបត្តិ នៃអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា (TPO Cambodia) ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយនាំមុខគេ ក្នុងវិស័យសុខភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា។ លោកបានបំរើការអស់រយៈពេល១៧ឆ្នាំ មកហើយ ក្នុងវិស័យចិត្តវិកល ហើយមានចំណាប់អារម្មណ៍ពិសេសលើសុខភាពសហគមន៍ ការប៉ះទង្គិចផ្លូវចិត្ត និងចិត្តវិកលអន្តរវប្បធម៌ក្នុងប្រទេសក្រោយសង្គ្រាម និងបរិបទក្រោយអំពើប្រល័យពូជសាសន៍។ លោក ក៏ជាសាស្ត្រចារ្យចិត្តវិកលវិទ្យា នៅដេប៉ាត់ម៉ង់ចិត្តវិទ្យា នៅសាកលវិទ្យាល័យភ្នំពេញ។ លោកបានទទួលអាហារូបករណ៍ភាពជាអ្នកដឹកនាំនៃប្រទេសអូស្ត្រាលី (Australian Leadership Award) ដើម្បីសិក្សាថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យម៉ូណាហ្ស ទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី។ ការងារស្រាវជ្រាវរបស់លោក

## ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្ដីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ស្ដីអំពីការអភិវឌ្ឍ និងការបញ្ជាក់នៃរោគសញ្ញាការប៉ះទង្គិចផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ដែលហៅថា "ជំងឺបាក់ស្បាត" ដែលតាមន័យអក្សរសាស្ត្រត្រូវបានបកប្រែថា "ជំងឺធ្លាក់ទឹកចិត្ត" ដែលជាប្រភេទជំងឺ Post Traumatic Stress Disorder។

**លោក CHUNG Chang-Ho** គឺជាចៅក្រមនៅអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានតែងតាំងដោយអង្គការសហប្រជាជាតិ ចាប់ពីខែសីហា ឆ្នាំ២០១១។ មុនពេលការតែងតាំងនេះ លោកបានបំរើការជាសេនានុព័ន្ធច្បាប់ប្រចាំស្ថានទូតសាធារណរដ្ឋកូរ៉េ និងជាបេសកជនអចិន្ត្រៃយ៍នៅទីក្រុងវីយ៉ែន។ ចាប់ពីឆ្នាំ២០០៤ លោកបានបំរើការជាចៅក្រមនៅតុលាការជាន់ខ្ពស់ក្នុងប្រទេសកូរ៉េខាងត្បូង។ មុនពេលនេះទៀត លោកបានបំរើការជាចៅក្រមនៅតុលាការថ្នាក់ស្រុកអស់រយៈពេល ៨ឆ្នាំ និងជាចៅក្រមនៅតុលាការសឹកអស់រយៈពេល ៣ឆ្នាំ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ និងថ្នាក់អនុបណ្ឌិតផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យជាតិសេអ៊ូល។ លោកក៏ជាអ្នកស្រាវជ្រាវជាន់ខ្ពស់មួយរូបនៅសាលាសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយនៃទីក្រុងឡុងដ៍ និងនៅសាកលវិទ្យាល័យហុងកុងផងដែរ។

**លោក COHEN David** គឺជាសាស្ត្រាចារ្យថ្នាក់ឧត្តមសិក្សានៅសាកលវិទ្យាល័យកាលីហ្វ័រនីញ៉ា ប៊ឺឃ្លី និងជានាយកស្ថាបនិកមជ្ឈមណ្ឌលសិក្សាឧក្រិដ្ឋកម្មសង្គ្រាមប៊ឺឃ្លី។ មុនពេលធ្វើជាសាស្ត្រាចារ្យ ចាប់ពីឆ្នាំ១៩៧៩ លោកបានប្រកបវិជ្ជាជីវៈអស់ពេលជា យូរនៅសាកលវិទ្យាល័យកាលីហ្វ័រនីញ៉ា ប៊ឺឃ្លី និងមានតំណាងជាសាស្ត្រាចារ្យនៃនាយកដ្ឋានវោហាសាស្ត្រផងដែរ។ ចាប់ពីឆ្នាំ២០០០ លោកបានសហការលើគម្រោងសិទ្ធិមនុស្សនៅអាស៊ីជាមួយមជ្ឈមណ្ឌល East West ទីក្រុង Honolulu ដែលជាមជ្ឈមស្រាវជ្រាវ អាស៊ីប៉ាស៊ីហ្វិកដែលបានផ្ដល់មូលនិធិរដ្ឋសហព័ន្ធ។ នៅទីនោះ លោកបំរើការជានាយកនៃអង្គការគំនិតផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិអាស៊ី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកច្បាប់អន្តរជាតិ។ លោកគឺជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន Hoover នៅសាកលវិទ្យាល័យ Sanford និងចាប់ពីឆ្នាំ ២០១២ ជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យ Hawaii។ នៅសាកលវិទ្យាល័យ Stanford មជ្ឈមណ្ឌលសិក្សាឧក្រិដ្ឋកម្មសង្គ្រាម និងបណ្ណាល័យនិងបណ្ណាសារ Hoover លោកបានសហការលើគម្រោងទុកឯកសារ និងបច្ចេកវិទ្យានៅប្រទេសកម្ពុជា ប្រទេសចិន និងជាមួយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី។ លោកសាស្ត្រាចារ្យក៏ធ្វើជាទីប្រឹក្សាប្រចាំមជ្ឈមណ្ឌលធនធានសិទ្ធិមនុស្ស ដែលជាបណ្ដាញសាកលវិទ្យាល័យអាស៊ាន នៅសាលកវិទ្យាល័យឥណ្ឌូនេស៊ី នាទីក្រុងហ្សាកាតា។

**លោកស្រីបណ្ឌិត DE LANGIS Theresa** គឺជាអ្នកប្រឹក្សាយោបល់អន្តរជាតិលើសិទ្ធិស្ត្រីក្នុងប្រទេសមានជម្លោះ ប្រទេសក្រោយជម្លោះ និងប្រទេសស្ថិតក្នុងតំណាក់កាលអន្តរកាល ដោយមានជំនាញពិសេសខាងផ្នែកអនុសញ្ញាស្ដីពីការរើសអើងប្រឆាំងនឹងស្ត្រី ភេទ (CEDAW), សេចក្ដីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ (UNSCR 1325) និងស្តង់ដារបទដ្ឋានផ្សេងៗ ដែលមានគោលបំណងដើម្បីធានាឲ្យមានកិច្ចការពារប្រកបដោយន័យដល់ស្ត្រីនៅក្នុងស្ថានភាពប្រទេសជម្លោះប្រដាប់អាវុធ និងការចូលរួមក្នុងដំណើរការសន្តិភាព និងសន្តិសុខយូរអង្វែង។ បច្ចុប្បន្ននេះ លោកស្រីស្ថិតនៅទីក្រុងភ្នំពេញ កំពុងស្រាវជ្រាវនិងសរសេរអំពីវិធានការសមរម្យដើម្បីដោះស្រាយចំពោះអំពើហិង្សាផ្លូវភេទនិងយ៉េនឌ័រ ដែលជាផ្នែកមួយនៃអំពើសាហាវឃោរឃៅនានា ប្រព្រឹត្តឡើងក្នុងរបបខ្មែរក្រហម។

**លោក ឌឹម សុវណ្ណារុំ** បច្ចុប្បន្នគឺជាប្រធានផ្នែកកិច្ចការសាធារណៈនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលតំណែងនេះចាប់ផ្ដើមពីខែមករា ឆ្នាំ២០១០។ មុនពេលក្លាយជាប្រធានផ្នែកកិច្ចការសាធារណៈ លោកគឺជាមន្ត្រីសារព័ត៌មាននៅអ.វ.ត.ក ចាប់ពីឆ្នាំ២០០៩-២០១១។ បន្ថែមលើការងាររបស់លោកនៅ អ.វ.ត.ក លោក សុវណ្ណារុំ ក៏បំរើការជាអ្នកផលិតវីដេអូវិជ្ជាជីវៈសម្រាប់រដ្ឋាភិបាល ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ ព្រមទាំងទទួលជាសាស្ត្រាចារ្យ និងបានបង្រៀនអំពីមុខវិជ្ជាទំនាក់ទំនងសាធារណៈ (ឆ្នាំ២០០៩-២០១១) នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងប្រព័ន្ធសោតទស្សន៍ (ឆ្នាំ២០០៧-២០០៨) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សម្រាប់ថ្នាក់អនុបណ្ឌិត (ចំពោះនិស្សិតដែលសិក្សាផ្នែកភាសាបារាំង)។ អស់រយៈពេលជាង ១៤ឆ្នាំមកនេះ លោកធ្លាប់ធ្វើជាអ្នកយកព័ត៌មាន និងជាអ្នកសម្របសម្រួលដ៏ល្បីឈ្មោះនៅទូរទស្សន៍ជាតិកម្ពុជា (TVK) ជាកន្លែងដែលលោក

## ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានផលិតកម្មវិធីទូរទស្សន៏រាប់រយជាភាសាខ្មែរនិងភាសាបារាំង ដូចជា កម្មវិធីទស្សនាវដ្តីទូរទស្សន៍ ឯកសារ និងខ្សែភាពយន្ត លើវិស័យជាច្រើន (កសិកម្ម ឧស្សាហ៍កម្ម កីឡា វប្បធម៌ ទេសចរណ៍ ។ល។) លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតនៅមជ្ឈមណ្ឌលសិក្សាផ្នែកការទូត និងយុទ្ធសាស្រ្ត (Centre d'Etudes Diplomatiques et Stratégiques) និងសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកសារព័ត៌មាននៅនាយកដ្ឋានភាសាបារាំងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**លោកស្រី DITRICH Viviane** បច្ចុប្បន្ន គឺជាអ្នកស្រាវជ្រាវថ្នាក់ក្រោយបញ្ចប់ឧត្តមសិក្សា នៅនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៅសាលាសេដ្ឋកិច្ច និងវិទ្យាសាស្រ្តនយោបាយនៃទីក្រុងឡុងដ៍។ ការស្រាវជ្រាវរបស់លោកស្រីផ្តោតលើស្ថាប័នអន្តរជាតិ ជាពិសេសសាលាក្តីឧក្រិដ្ឋកម្ម(ដែលមានលក្ខណៈ)អន្តរជាតិ និង យុត្តិធម៌ និងសន្តិភាពក្រោយជម្លោះ។ លោកស្រីបាននឹងកំពុងពិនិត្យអំពីការវិវឌ្ឍផ្នែកស្ថាប័ននៃសាលាក្តីពិសេសជាច្រើន ក្នុងការឈានឆ្ពោះទៅរកការបិទបញ្ចប់ដំណើរការ និង ការគិតគូរអំពីបញ្ហាកេរដំណែល។ នាពេលបច្ចុប្បន្នលោកស្រីកំពុងបំរើការជាជំនួយការសាស្រ្តាចារ្យនៅសាលាសេដ្ឋកិច្ច និងវិទ្យាសាស្រ្តនយោបាយនៃទីក្រុងឡុងដ៍ និងមុនពេលនេះ បានបំរើការជាសមាជិកបុគ្គលិកបណ្តោះអាសន្ននៅវិទ្យាស្ថានអប់រំអន្តរជាតិនៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី ក្នុងឋានៈជាជំនួយការសាស្រ្តាចារ្យនៅមហាវិទ្យាល័យ Wellesley និងជាសមាជិកគម្រោង Afric@ction ដែលជាគម្រោងជំនួយអភិវឌ្ឍន៍ផ្តោតលើប្រទេសនីហ្សេ។ លោកស្រី Viviane បានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកទំនាក់ទំនងអន្តរជាតិ ពីសាលាសេដ្ឋកិច្ច និងវិទ្យាសាស្រ្តនយោបាយនៃទីក្រុងឡុងដ៍ និងសញ្ញាប័ត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្រ្តនយោបាយ ពីសាកលវិទ្យាល័យនៅទីក្រុងប៉ារីស( សញ្ញាប័ត្រពីរ )។

**លោក DOWNING Rowan** គឺជាចៅក្រមនៅអង្គបុរេជំនុំជម្រះដែលត្រូវបានតែងតាំងដោយអង្គការសហប្រជាជាតិ។ លោកជាមេធាវីជាន់ខ្ពស់សញ្ជាតិអូស្រ្តាលី និងបានទទួលតំណែងច្បាប់ជាន់ខ្ពស់នៅក្នុងតំបន់ប៉ាស៊ីហ្វិក ព្រមទាំងធ្វើជាចៅក្រមនៅសាលាឧទ្ធរណ៍ និងតុលាការកំពូលនៃក្រុង Vanuatu ដែលភាគច្រើនជារឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី ។ លោកបានធ្វើការជាលក្ខណៈអន្តរជាតិ ក្នុងវិស័យកំណែទម្រង់ច្បាប់អស់រយៈពេល២០ឆ្នាំ (ដោយផ្តោតលើច្បាប់ព្រហ្មទណ្ឌនិងច្បាប់ពាណិជ្ជកម្ម), ច្បាប់សិទ្ធិមនុស្ស, ការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សនៅក្នុងសន្ធិសញ្ញា, ច្បាប់ស្តីពីជនភៀសខ្លួន, ច្បាប់រដ្ឋបាល, ច្បាប់ប្រឆាំងអំពើពុករលួយ និង ការស៊ើបអង្កេត និងការកាត់ទោសឧក្រិដ្ឋកម្មឆ្លងដែន។ លោក ក៏បានធ្វើការជាមួយអង្គការពហុតោភាគីមួយចំនួនដើម្បីធ្វើឲ្យប្រសើរឡើងនូវឯករាជ្យភាពនៃតុលាការ និងបូរណភាពជាប្រព័ន្ធនៅក្នុងប្រព័ន្ធច្បាប់នៅប្រទេសផ្សេងៗជាច្រើន។ លោកជាមេធាវីការពារសិទ្ធិមនុស្ស និងជាអ្នកផ្តល់យោបល់ដំបូន្មានដល់រដ្ឋាភិបាលទាក់ទងនិងសិទ្ធិស្រ្តី និងកុមារ។ លើសពីនេះ លោកធ្លាប់មានបទពិសោធន៍បណ្តុះបណ្តាលមេធាវី និងមន្រ្តីតុលាការក្នុងតំបន់អាស៊ីអាគ្នេយ៍និងប៉ាស៊ីហ្វិក ផងដែរ។ លោកបានផ្តល់ការបណ្តុះបណ្តាលជាច្រើនដល់កងការពារអូស្រ្តាលីទាក់ទងនឹងច្បាប់ឧក្រិដ្ឋកម្មសង្រ្គាម, សិទ្ធិមនុស្ស និងច្បាប់សង្រ្គាម។

**លោកស្រី DUFFY Clair** គឺជាមេធាវីសញ្ជាតិអូស្រ្តាលី-ស្កុតឡែន និងបានកំពុងឃ្លាំមើលដំណើរការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អស់រយៈពេល២ឆ្នាំហើយ ក្នុងនាមឲ្យអង្គការគំនិត ផ្តួចផ្តើមយុត្តិធម៌សង្គមសេរី ដែលមានមូលដ្ឋាននៅទីក្រុងញូយ៉ក សហរដ្ឋអាមេរិក។ នៅមុនពេលចូលកាន់តំណែងនេះ លោកស្រីបានចំណាយពេលជាង៥ឆ្នាំជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ទីក្រុងអារ៉ូហ្សា ប្រទេសតង់ហ្សានា។ ជីវប្រវត្តិផ្នែកច្បាប់អន្តរជាតិរបស់លោកស្រីពីមុន គឺថាលោកស្រីធ្លាប់ជាព្រះរាជអាជ្ញាសហព័ន្ធរបស់ប្រទេសអូស្រ្តាលី។

**លោក ដួង សាវន** គឺជាអ្នកសម្របសម្រួលសម្រាប់គម្រោងហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហមនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP)។ ចាប់ពីឆ្នាំ២០០៧ ដល់ ឆ្នាំ២០០៩ លោកបានបំរើការជាអ្នកសម្របសម្រួលការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងខ្សែភាពយន្តរបស់ អ.វ.ត.ក នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)។ លោកក៏ធ្លាប់ជាសាស្រ្តាចារ្យនៅសាកលវិទ្យាល័យមួយចំនួននៅរាជធានីភ្នំពេញ ហើយលោកបានសរសេរ និងបោះពុម្ពសៀវភៅស្តីពីហិង្សាផ្លូវភេទជាច្រើនពាក់ព័ន្ធនឹងជនរងគ្រោះ និងសាក្សី ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។ លោក

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកែរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានទទួលសញ្ញាប័ត្របរិញ្ញាផ្នែកអប់រំភាសាអង់គ្លេសនៅវិទ្យាស្ថានភាសាបរទេស (IFL) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកច្បាប់អន្តរជាតិ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (PUC)។

**លោក HANSEN Florian** គឺជាសហស្ថាបនិក និងជាអ្នកសម្របសម្រួលនៃកម្មវិធីឃ្លាំមើលសាលាក្តីនៅសាកលវិទ្យាល័យ Marburg ប្រទេសអាល្លឺម៉ង់។ ការទទួលខុសត្រូវចំបងរបស់លោក រួមមាន ការធានាការច្របាច់បញ្ចូលគ្នានូវកម្មវិធីនៅមហាវិទ្យាល័យផ្សេងគ្នាជាច្រើននៅសាកលវិទ្យាល័យដែលមានដូចជា សកម្មភាពជ្រើសតាំង ការរៀបចំអ្នកឃ្លាំមើលសម្រាប់ការងារនៅតាមទី កន្លែងចុះធ្វើការ និងសម្រេចចិត្តលើបុគ្គលិក ជាដើម។ លោក **Hansen** ក៏ជាស្មាក្តីហាត់ការនៅតុលាការថ្នាក់ស្រុក Gieben។ នៅមុនពេលប្រកបវិជ្ជាជីវៈបច្ចុប្បន្ននេះ លោក Hansen ធ្លាប់បានធ្វើជាអ្នកឃ្លាំមើលការជំនុំជម្រះក្តីរបស់អ.វ.ត.ក របស់អង្គការផ្តួចផ្តើមយុត្តិធម៌អន្តរជាតិនៅអាស៊ី (AIJI)។

**លោក HANSEN Tom Barthel** គឺអ្នកតំណាងនៃស្ថានទូតព្រះរាជាណាចក្រដាណឺម៉ាកនៅភ្នំពេញ, DANIDA។ កាលពីមុន លោកបានបំរើការជាប្រធានទីប្រឹក្សាបច្ចេកទេសសម្រាប់ទីភ្នាក់ងារ DANIDA សម្រាប់លេខាធិការអចិន្ត្រៃយ៍ ប្រចាំនៅក្រសួង សេដ្ឋកិច្ច Lesotho និងសម្រាប់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ប្រចាំនៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា។ លោកធ្លាប់ធ្វើការនៅក្រសួង ការបរទេសនៃប្រទេសដាណាម៉ាក ចាប់តាំងពី១៩៩២។ លើសពីនេះទៀត លោកធ្លាប់បានធ្វើការនៅស្ថាទូតដាណាម៉ាក ប្រចាំ នៅប្រទេសមួយចំនួនដូចជា នៅប្រទេសនីការ៉ាហ្គ័រ (ជាឯកអគ្គរដ្ឋទូត) នៅប្រទេសបង់ក្លាដេស (ជាអនុប្រធានបេសកកម្ម)។ នៅមុនពេលចូលតំណែងនៅស្ថានទូតដាណាម៉ាក ប្រចាំនៅប្រទេសកម្ពុជា លោកធ្លាប់ជាប្រធាននាយកដ្ឋានសម្រាប់ការធានារ៉ាប់រងគុណភាពនៃជំនួយអភិវឌ្ឍន៍នៃក្រសួងកិច្ចការបរទេស នៅCopenhagen។ ប្រទេសដាណឺម៉ាកបានផ្តល់វិភាគទានថវិកា ចំនួន៣លាន ដេនីសក្រូណឺ (ប្រហែល ៥00,000 ដុល្លារសហរដ្ឋអាមេរិក) ដល់សាលាក្តីខ្មែរក្រហម។ DANIDA គឺជាអ្នកសម្របសម្រួលម្ចាស់ជំនួយនាំមុខ នៃក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។

**លោកវេជ្ជបណ្ឌិត HANSEN Steen-Holger** (កម្ពុជា) បំរើការជាអនុប្រធានផ្នែកនីតិវេជ្ជសាស្ត្រខាងវិកលវិទ្យានៅសាកលវិទ្យាល័យ Copenhagen ប្រទេសដាណឺម៉ាក ជាទីដែលលោកបានបំរើការចាប់តាំងពីឆ្នាំ១៩៩៨មក។ លោកវេជ្ជបណ្ឌិត គឺជា អ្នកឯកទេសខាងកាយវិភាគជំងឺសតិជាលិកាវិទ្យា និងជាអ្នកឯកទេសនីតិវេជ្ជសាស្ត្រ។ ចាប់ពីឆ្នាំ២០០១ ផ្ទាល់ខ្លួន ឬក្នុងឋានៈជាអ្នកគ្រប់គ្រងម្នាក់ធ្លាប់បានធ្វើការពិនិត្យអ្នករស់រានមានជីវិតនៃអំពើទារុណកម្មនិងការធ្វើបាបផ្សេងៗរាប់រយនាក់ជុំវិញពិភពលោក។ លោកធ្លាប់ជាជនសកម្មក្នុងបេសកកម្មស្វែងរកការពិត នៅអតីតប្រទេសយូហ្គោស្លាវី ប៉េរូ រ៉ូវ៉ានដា និងកម្ពុជា។

**លោក HEENAN James** គឺជាតំណាងស្តីទីនៃការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា។ លោកបានបំរើការក្នុងមុខតំណែងផ្សេងៗជាច្រើន នៅការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងអំឡុងទសវត្សរ៍កន្លងទៅនេះ លើបញ្ហាអេដស៍ នីតិរដ្ឋ និងជាសមាជិកលេខាធិការដ្ឋានក្រុមប្រឹក្សាសិទ្ធិមនុស្ស។ លោកធ្លាប់បានដឹកនាំលេខាធិការដ្ឋានបេសកកម្មរបកគំហើញ ដែលដឹកនាំដោយ Archbishop Desmond Tutu ក្នុងករណីបាញ់ភ្លោងលើភូមិ Beit Hanoun នៅក្នុងដែនដីដែលបានកាន់កាប់របស់កាហ្សាក្នុងឆ្នាំ២០០៧ និងជាសមាជិកគណៈកម្មការស៊ើបអង្កេតអំពើហឹង្សាស្អប់ជនបរទេស នៅប្រទេសអាហ្វ្រិកខាងត្បូងក្នុងឆ្នាំ២០០៩។ មុនការចូលបំរើការនៅអង្គការសហប្រជាជាតិ លោក Heenan គឺជាសមាជិកនាយកដ្ឋានច្បាប់នៅសាកលវិទ្យាល័យទ្វីបអឺរ៉ុបនៅទីក្រុង Florence ប្រទេសអ៊ីតាលី។ លោកត្រូវបានទទួលស្គាល់ឲ្យប្រកបវិជ្ជាជីវៈជាមេធាវីនៅប្រទេសអូស្ត្រាលី និងអង់គ្លេស និងទទួលសញ្ញាប័ត្រនៅសាកលវិទ្យាល័យ និងសាកលវិទ្យាល័យទ្វីបអឺរ៉ុប។

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**លោកស្រី HEINDEL Anne** ធ្លាប់ជាទីប្រឹក្សាច្បាប់ប្រចាំមជ្ឈមណ្ឌលឯកសារកម្ពុជា(DC-Cam) ចាប់ពីឆ្នាំ២០០៧។ លោកស្រីគឺជាអ្នកសរសេរអត្ថបទវិភាគ ប្រចាំសប្តាហ៍ស្តីពីរបកគំហើញច្បាប់ អ.វ.ត.ក សម្រាប់គម្រោងអ្នកឃ្លាំមើលសាលាក្តីកម្ពុជា (http://www.cambodiatribunal.org/commentary/expert-commentary-legal-filings) និងជាសហអ្នកនិពន្ធសៀវភៅ ស្តីពី *"យុត្តិធម៌ចម្រុះ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"* ដែលត្រូវបោះពុម្ពដោយសាកលវិទ្យាល័យ Michigan Press នៅក្នុងឆ្នាំ២០១៣។ មុនពេលមកកាន់ប្រទេសកម្ពុជា លោកស្រីធ្លាប់ជាជំនួយការនាយក នៃការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាមនៅមហាវិទ្យាល័យច្បាប់វ៉ាស៊ីនតោន នៃសាកលវិទ្យាល័យអាមេរិកាំង ។

**លោកស្រី ហេង យូឡេង** គឺជាអ្នកគ្រប់គ្រងសំណុំរឿងសម្រាប់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅផ្នែកគាំពារជនរងគ្រោះ (VSS) របស់អង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ លោកស្រី ក៏ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយធ្លាប់បំរើការនៅអង្គការមិនមែនរដ្ឋាភិបាលជាច្រើន និងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF)។

**លោក ហុង គឹមសួន** គឺជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅមុខអ.វ.ត.ក ចាប់ពីឆ្នាំ២០០៧។ លោកបានប្រកបវិជ្ជាជីវៈច្បាប់ព្រហ្មទណ្ឌចាប់ពីឆ្នាំ១៩៩៤។ លោក **ហុង គឹមសួន** បានចូលជាមេធាវីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ១៩៩៧។ លោកធ្លាប់ជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី នៅឆ្នាំ២០០៦។ លោក ហុង គឹមសួន បានបំរើការជាមេធាវីការពារក្តីនៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ចាប់ពីឆ្នាំ១៩៩៤ រហូតដល់បច្ចុប្បន្ន និងត្រូវបានតែងតាំងឲ្យធ្វើជាប្រធានក្រុមមេធាវីនិងជាសមាជិកគណៈកម្មាធិការប្រតិបត្តិនៃអង្គការផងដែរ នៅឆ្នាំ២០០៦។ ក្នុងឆ្នាំ ២០០៩ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកនីតិសាធារណៈ។

**លោក ហួត វុទ្ធី** គឺជាចៅក្រមនៅអង្គបុរេជំនុំជម្រះ នៃអ.វ.ត.ក ចាប់ពីឆ្នាំ២០០៦។ ពីមុននេះ លោកបានបំរើការជាព្រះរាជអាជ្ញា នៅតុលាការខេត្តកណ្តាលចាប់ពីឆ្នាំ២០០១។ បន្ថែមពីលើតួនាទីរបស់លោកក្នុងតុលាការ លោកបានបង្រៀន អប់រំច្បាប់ដល់សហគមន៍ និងបណ្តុះបណ្តាលមន្ត្រីមូលដ្ឋានអំពីច្បាប់កម្ពុជា រួមទាំងច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌ។ ក្នុងឆ្នាំ២០០១ លោក ហួត វុទ្ធី ត្រូវបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដោយរាជរដ្ឋាភិបាលកម្ពុជា។ លោកទទួលបានអនុបណ្ឌិតផ្នែកនីតិសាស្ត្រពីសាកលវិទ្យាល័យក្រុង Metchninos នៃទីក្រុង Odessae ប្រទេសអ៊ុយក្រែន ក្នុងឆ្នាំ១៩៩៤ ហើយចាប់ពីឆ្នាំ១៩៩៦ លោកជាសាស្ត្រាចារ្យច្បាប់នៅសាលកវិទ្យាល័យ Norton។ លោកធ្លាប់ធ្វើ ជាទីប្រឹក្សាច្បាប់សម្រាប់គម្រោងស្តីពីការស្រាវជ្រាវអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ។

**លោក អ៊ឹម សុភា** គឺជាប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ពីឆ្នាំ២០១០។ មុនពេលនេះ លោកបានបំរើការជាទីប្រឹក្សាយោបល់សេរី (IS&DC) ជានាយករងនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈ ពី មហាវិទ្យាល័យគោលនយោបាយនិងរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យកម្ពុជាក្នុងឆ្នាំ២០០៥ និងបរិញ្ញាប័ត្រផ្នែកបង្រៀនភាសាអង់គ្លេស ពីវិទ្យាស្ថានភាសាបរទេស (IFL) នៃសាលកវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ១៩៩៨។

**លោកស្រីបណ្ឌិត JARVIS Helen** បានមកទស្សនកិច្ចប្រទេសកម្ពុជា ជាលើកដំបូងក្នុងឆ្នាំ១៩៦៧ ប៉ុន្តែវាមានរយៈពេល២០ឆ្នាំ មុនពេលដែលលោកស្រីបានវិលត្រឡប់មកជួយកសាងបណ្ណាល័យជាតិរបស់ប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ១៩៩៥-២០០១ លោកស្រីធ្លាប់ជាអ្នកប្រឹក្សាយោបល់លើឯកសារសម្រាប់កម្មវិធីប្រល័យពូជសាសន៍កម្ពុជានៅសាកលវិទ្យាល័យយេល។ លោកស្រី គឺជាទីប្រឹក្សាឲ្យរាជរដ្ឋាភិបាលកម្ពុជា និងបានបំរើការចាប់ពីឆ្នាំ១៩៩៩ ជាមួយក្រុមការងារស្តីពីសាលាក្តីខ្មែរក្រហម ដែលមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ជាប្រធាន។ លោកស្រីបណ្ឌិត Jarvis គឺជាប្រធានផ្នែកកិច្ចការសាធារណៈដំបូងគេ និងបន្ទាប់មកជាប្រធានផ្នែគាំពារជនរងគ្រោះនៅ

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០។ ក្នុងឆ្នាំ២០០៤ លោកស្រីបណ្ឌិត បាននិពន្ធរួមគ្នាជាមួយ Tom Fawthrop នូវសៀវភៅ ស្តីអំពី "Getting away with genocide? Elusive Justice and the Khmer Rouge Trials"។ លោកស្រីបានទទួលសញ្ញាប័ត្របណ្ឌិតសម្រាប់ការសិក្សាអំពីប្រទេសឥណ្ឌូនេស៊ី និង នៅមុននេះទៀត លោកស្រី ធ្លាប់ធ្វើជាសាស្ត្រាចារ្យ និងជាប្រធានសាលាព័ត៌មានបណ្ណាល័យ និងបណ្ណាសារ នៅសាកលវិទ្យាល័យ New South Wales ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។

**លោកស្រី JORGENSEN Nina** គឺជាជំនួយការសាស្ត្រាចារ្យ នៅមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យហុងកុង ប្រទេសចិនចាប់ពីឆ្នាំ២០១០។ នៅមុននេះ លោកស្រីបានធ្វើការអស់រយៈពេល៨ឆ្នាំ ក្នុងតំណែងខុសៗ គ្នា (ស្ថាប័នអយ្យការ សភាចៅក្រម អង្គភាពការពារក្តី) នៅតុលាការពិសេសសម្រាប់សេរ៉ាឡេអូន នៅទីក្រុង Freetown និងទីក្រុងឡាអេ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ភ្នំពេញ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ៉ូវ៉ាន់ដា នៅទីក្រុង ឡាអេ និងអារូសា។ លោកស្រីក៏ធ្លាប់បំរើការឲ្យការិយាល័យ OSCE សម្រាប់វិទ្យាស្ថានប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅទីក្រុង Warsaw ដែលនៅទីនោះ លោកស្រី គឺជាទីប្រឹក្សាច្បាប់សម្រាប់ការអត់ឱន និងការមិនរើសអើង។ មុនពេលចាត់តាំងឲ្យធ្វើការនេះ លោកស្រីជាអ្នកស្រាវជ្រាវត្រៀមបញ្ចប់ថ្នាក់បណ្ឌិតផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅសាកលវិទ្យាល័យ Leiden ។ លោកស្រី ទទួលបានសញ្ញាប័ត្របរិញ្ញាប័ត្រ (Bristol) និងសញ្ញាប័ត្របណ្ឌិតនៅសាកលវិទ្យាល័យ Oxford។ ប្រធានបទថ្នាក់បណ្ឌិតរបស់លោកស្រីមានឈ្មោះថា "The Responsibility of State for International Crimes" ធ្លាប់ត្រូវបានបោះពុម្ពផ្សាយនៅសាកលវិទ្យា London ហើយលោកស្រីបានបោះពុម្ពផ្សាយឯកសារជាច្រើន នៅក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ លោកស្រី មានសញ្ញាប័ត្រប្រកបវិជ្ជាជីវៈច្បាប់ ហើយបច្ចុប្បន្នជាមេធាវី និងមានមុខនាទីនៅសភា Argent ទីក្រុងឡុងដ៍។

**លោក KARNAVAS Michael G** គឺជាមេធាវីដែលមានបទពិសោធន៍រយៈពេល៣០ឆ្នាំ ក្នុងរឿងក្តីព្រហ្មទណ្ឌ។ ក្នុងឋានៈជាសហមេធាវីអន្តរជាតិរបស់ លោក **អៀង សារី** នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាមេធាវីនាំមុខឲ្យលោកបណ្ឌិត **Jadrako Prlic** និងលោកវរសេនីយឯក **Vidoje Blagojevic** នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី **(ICTY)** លោក **KARNAVAS** មានបទពិសោធន៍ជាង១១ឆ្នាំ ក្នុងករណីរឿងក្តីឧក្រិដ្ឋកម្មអន្តរជាតិដែលស្មុគ្រស្មាញ និងមានច្រើនភាគី។ អស់រយៈពេល២២ឆ្នាំនេះ លោកបានបង្រៀនអំពីជំនាញតស៊ូមតិនៅក្នុងសវនាការដល់មេធាវីជាច្រើននៅក្នុងកម្មវិធីនិងស្ថាប័នផ្សេងៗគ្នា រួមមាន សាលាការពារក្តីឧក្រិដ្ឋកម្មសាលាច្បាប់ Cardozo និងមជ្ឈមណ្ឌល Grotious នៃសាកលវិទ្យាល័យ Leiden។ លោកក៏បានចូលរួមក្នុងកិច្ចពិភាក្សាតុមូលអំពីច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិនិងនីតិវិធី និងបានចូលរួមជាអ្នកប្រឹក្សាផ្តល់ យោបល់ដល់តុលាការក្នុងរឿងក្តីស្មុគ្រស្មាញផងដែរ។ លោកបានបោះពុម្ពផ្សាយអត្ថបទជាច្រើនស្តីអំពី ច្បាប់អន្តរជាតិ និងនីតិវិធី និងសៀវភៅស្តីពីការតស៊ូមតិក្នុងសវនាការ។ ចាប់ពីឆ្នាំ១៩៩១ ដល់ឆ្នាំ២០០១ លោកជានាយកប្រតិបត្តិ និងជាប្រធាន គណៈកម្មការវិសោធនកម្មច្បាប់ Brcko (BLRC) ក្នុងឋានៈជាអ្នកដឹកនាំការងារកែទម្រង់តុលាការ គណៈកម្មការនេះបានព្រាង និង ធ្វើវិសោធនកម្មច្បាប់ និងនីតិវិធីជាធរមាន ដើម្បីបង្កើតជាប្រព័ន្ធច្បាប់រួមមួយនៅក្នុងទូទាំងស្រុក Brcko នៃប្រទេស បូស្នី និង ហេស្សេហ្គូវេនី ដែលបង្កើតដោយ កិច្ចព្រមព្រៀងតុលាការ Dayton (សូមមើល ការបង្កើតក្របខណ្ឌច្បាប់នៅស្រុក Brcko នៃប្រទេសបូស្នី និងហេស្សេហ្គូវេនី៖ គំរូសម្រាប់តំបន់ និងប្រទេសក្រោយសង្គ្រាម, ទស្សនាវដ្តីច្បាប់អាមេរិកាំង, វ៉ុល៩៧ លេខ១ (ខែមករា ២០០៣), ទំព័រ១១១-១៣១។

**លោកស្រី KLONOWIECKA-MILART Agnieszka** គឺជាចៅក្រមនៅអង្គជំនុំជម្រះតុលាការនៅ អ.វ.ត.ក ដែលបានតែងតាំងដោយអង្គការសហប្រជាជាតិ។ មុនពេលការតែងតាំងនេះ លោកស្រីជាចៅក្រម ដែលបានតែងតាំងដោយអង្គការសហប្រជាជាតិនៅក្នុងបេសកកម្មរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ ជាកន្លែងដែលលោកស្រីបានត្រូវតែងតាំងជាចៅក្រមនៅតុលាការកំពូលកូសូវ៉ូ ដើម្បីធ្វើការវិនិច្ឆ័យទៅលើឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើភេរវកម្ម និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាច្រើនទៀត។ មុនពេលការតែងតាំងជាចៅក្រមអន្តរជាតិ លោកស្រី **KLONOWIECKA-MILART** ជាជំនួយការសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ នៅសាកលវិទ្យាល័យច្បាប់ក្នុងក្រុង Lublin ប្រទេសប៉ូឡូញ។ លោកស្រីបានចូលបំរើការនៅស្ថាប័នតុលាការនៅ

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឆ្នាំ១៩៩១ ហើយលោកស្រីត្រូវបានជ្រើសតាំងជាច្រើនដងឲ្យធ្វើការនៅក្រសួងយុត្តិធម៌ដោយធ្វើការសម្របច្បាប់ប៉ុឡូញឲ្យស្របតាមស្តង់ដារច្បាប់អន្តរជាតិ ដែលសំខាន់នោះគឺអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងច្បាប់សហភាពអឺរ៉ុប។ ចាប់ពីឆ្នាំ១៩៩៨ លោកស្រីបានចូលរួមយ៉ាងសកម្ម នៅក្នុងកំណែទម្រង់នីតិរដ្ឋ រួមមាន កម្មវិធីកំណែទម្រង់ច្បាប់និងតុលាការ របស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសបូស្នីម៉ាសេដូនី និងអាហ្វហ្គានីស្ថាន។

**លោក គង់ សុភី** គឺជាប្រធានផ្នែកគ្រប់គ្រងតុលាការ នៅ អ.វ.ត.ក។ ជាដំបូង លោកបានត្រូវតែងតាំងជាអ្នកបកប្រែភាសានៅ អ.វ.ត.ក ដោយក្រឹត្យរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦។ មុនការចូលរួមនៅ អ.វ.ត.ក លោកបានកាន់មុខតំណែងជាច្រើននៅទីស្តីការគណៈរដ្ឋមន្ត្រី រួមមានដូចជា៖ ជាអគ្គលេខាធិការរង នៃក្រុមប្រឹក្សាសម្រាប់កំណែទម្រង់រដ្ឋបាល អនុប្រធាននាយកដ្ឋាន និងជានាយកនៃកម្មវិធីក្រុមបេសកកម្មអាទិភាព (PMG) នាយកគម្រោងអភិបាលកិច្ច សហការជាមួយដៃគូអភិវឌ្ឍន៍ ជាអ្នកបកប្រែភាសាសម្រាប់លេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រងរដ្ឋបាល និងជាជំនួយការអ្នកគ្រប់គ្រងកម្មវិធីសម្រាប់កម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល។ លោក គង់ សុភី បានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងសាធារណៈនៅសាកលវិទ្យាល័យ Potsdam ប្រទេសអាល្លឺម៉ង់ សញ្ញាប័ត្រមន្ត្រីការទូតរដ្ឋបាលសាធារណៈជាន់ខ្ពស់នៅសាលាភូមិន្ទរដ្ឋបាល និងសញ្ញាប័ត្របរិញ្ញាប័ត្រចំនួនពីរ គឺបរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រពីមហាវិទ្យាល័យច្បាប់និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង បរិញ្ញាប័ត្រផ្នែកគ្រប់គ្រង ពីវិទ្យាស្ថានជាតិគ្រប់គ្រងនៅរាជធានីភ្នំពេញ។

**ឯកឧត្តម គង់ ស្រ៊ីម** ត្រូវបានតែងតាំងជាប្រធានអង្គជំនុំជម្រះតុលាការកំពូល និងជាចៅក្រមជាតិប្រចាំការនៅ អ.វ.ត.ក ដោយព្រះរាជក្រឹត្យចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦។ មុនពេលចូលកាន់តួនាទីនេះ ឯកឧត្តម ជាអគ្គព្រះរាជអាជ្ញារងនៃការិយាល័យអយ្យការអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញានៃការិយាល័យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុប្រធានការិយាល័យអយ្យការនៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ និងជាមន្ត្រីក្រសួងយុត្តិធម៌។ ឯកឧត្តមធ្លាប់ត្រូវបានតែងតាំងជាអនុប្រធានតុលាការកំពូល និងជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ឯកឧត្តម ក៏ជាសាស្ត្រាចារ្យផ្នែកច្បាប់នៅសាកលវិទ្យាល័យជាច្រើនក្នុងទីក្រុងភ្នំពេញផងដែរ។ ឯកឧត្តមបានទទួលបរិញ្ញាប័ត្រច្បាប់ពីមហាវិទ្យាល័យផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យទីក្រុងហូជីមិញ ប្រទេសវៀតណាម និង សញ្ញាប័ត្រអនុបណ្ឌិតឯកទេសនីតិឯកជន ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រាជធានីភ្នំពេញ។

**ឯកឧត្តម ក្រាញ់ តូនី** គឺជាប្រធានការិយាល័យរដ្ឋបាលស្តីទី នៅអ.វ.ត.ក ចាប់ពីឆ្នាំ២០០៩។ ឯកឧត្តមបានត្រូវតែងតាំងជានាយកបម្រុង និងប្រធានផ្នែកគ្រប់គ្រងតុលាការរបស់ អ.វ.ត.ក ចាប់ពីឆ្នាំ២០០៦ រហូតដល់ខែធ្នូ ឆ្នាំ២០០៩។ ឯកឧត្តមបានទទួលការបណ្តុះបណ្តាលនៅប្រទេសបារាំង និងវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ១៩៩៣ ជាពេលវេលាដែលឯកឧត្តមបានចូលរួមជាទីប្រឹក្សាច្បាប់ប្រចាំក្រុមការងារគណៈកម្មាធិការសភាធម្មនុញ្ញក្រោយការបោះឆ្នោតថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩៣ រៀបចំក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ។ ចាប់ពីពេលនោះមក ឯកឧត្តមបានបំរើការនៅការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី ហើយបានទទួលបន្ទុកបន្តគ្នាលើមុខតំណែងដូចជា៖ ចាប់ពីឆ្នាំ១៩៩៤-២០០១ ជាទីប្រឹក្សាច្បាប់ឲ្យទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ជាទីប្រឹក្សាឲ្យក្រុមការងាររដ្ឋាភិបាលសម្រាប់សាលាក្តីខ្មែរក្រហម និងចាប់ពីឆ្នាំ២០០៤ ឯកឧត្តមបានត្រូវតែងតាំងជាអនុរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី។ ឯកឧត្តមក៏ជាមេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម **ក្រាញ់ តូនី** បានបញ្ចប់ការសិក្សាផ្នែកច្បាប់នៅសាកលវិទ្យាល័យ Paris I Pantheon-Sorbonne: សញ្ញាប័ត្របរិញ្ញាប័ត្រច្បាប់ធុរកិច្ចនិងការងារ (ឆ្នាំ១៩៨៩) សញ្ញាប័ត្រអនុបណ្ឌិតផ្នែកនីតិសង្គម (ឆ្នាំ១៩៩០) និង សញ្ញាប័ត្របណ្តុះបណ្តាលរដ្ឋបាល (ឆ្នាំ១៩៩២)។ ឯកឧត្តម **ក្រាញ់ តូនី** រួមជាមួយនាយករងការិយាល័យរដ្ឋបាលផ្តល់កិច្ចសហការ និងការណែនាំទៅដល់គ្រប់ផ្នែក និងអង្គភាពនៅក្នុងការិយាល័យរដ្ឋបាល ដើម្បីធានាថាដំណើរការតុលាការត្រូវបានគាំទ្រយ៉ាងពេញលេញ។ ឯកឧត្តមក៏ទទួលបន្ទុកក្នុងការទាក់ទងជាមួយភាគីនានានៃកិច្ចព្រមព្រៀង និងសហគមន៍ម្ចាស់ជំនួយនានា។ ឯកឧត្តមត្រូវបានជួយគាំទ្រដោយមន្ត្រីច្បាប់ ដែលផ្តល់យោបល់ដល់ការិយាល័យរដ្ឋបាលលើក្របខណ្ឌដែលអនុវត្តទៀងទាត់ ព្រមទាំងការធ្វើសេចក្តីព្រាង និងធ្វើការត្រួតពិនិត្យឡើងវិញនូវឯកសារផ្លូវការនានា។

## ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**លោកបណ្ឌិត ឡៅ ម៉ុងហៃ** គឺជាអ្នកធ្វើការអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលនិវត្តន៍ និងជាអ្នកកំពុងតាមដានសវនាការ សំណុំរឿង ០០២ នៅអ.វ.ត.ក ជាប្រចាំ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ដល់ការបង្កើតពិតប្រាកដនៃអ.វ.ត.ក លោកបណ្ឌិតបានតស៊ូមតិជាសាធារណៈចំពោះការបង្កើតសាលាក្តីមួយ ដើម្បីកាត់ក្តីមេដឹកនាំខ្មែរក្រហម ដោយយកលំនាំតាមសាលាក្តីនៅ Nuremberg។ លោកធ្លាប់ជាប្រតិភូទៅកាន់ដំណើរការសន្តិភាព ដែលបានបញ្ចប់នៅក្នុងឆ្នាំ១៩៩១ ជាមួយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបានឈានទៅដល់បញ្ចប់ជម្លោះនៅក្នុងប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ១៩៩៥ រហូតដល់ពេលចូលនិវត្តន៍របស់លោកក្នុងឆ្នាំ២០០៩ លោកបណ្ឌិតបានចូលរួមយ៉ាងសកម្មនៅក្នុងការបណ្តុះបណ្តាល និងក្នុងការតស៊ូមតិអំពី នីតិរដ្ឋ សិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ និងការឃ្លាំមើលតុលាការ នៅប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០០៣ លោកជាសាស្ត្រាចារ្យទស្សនៈកិច្ចនៅសាកលវិទ្យាល័យតូរ៉ុនតូ ប្រទេសកាណាដា។ នៅទីនោះ លោកបណ្ឌិតបានបង្រៀនមុខវិជ្ជានយោបាយអាស៊ីពីរឆមាសបន្តគ្នា។ ក្នុងឆ្នាំ២០០៧ លោកបានទទួលរង្វាន់ពីអង្គការឃ្លាំមើលសិទ្ធិមនុស្សសម្រាប់ការងារសិទ្ធិមនុស្សរបស់លោក និងក្នុងឆ្នាំ២០០២ មេដាយ Nansen ពីឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនសម្រាប់ការងាររបស់លោកលើការងារជនភៀសខ្លួន។

**លោក ឡាត់ គី** បានបំរើការនៅសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) ជាអ្នកឃ្លាំមើល/អ្នកស៊ើបអង្កេតសិទ្ធិមនុស្ស និងអ្នកតស៊ូមតិចាប់ពីឆ្នាំ១៩៩៦។ ចាប់ពីឆ្នាំ២០០៨ លោកជាអ្នកសម្របសម្រួលកម្មវិធីសាលាក្តីខ្មែរក្រហមនិងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ លោកបានធ្វើការផ្សព្វផ្សាយឲ្យមានការយល់ដឹងអំពី អ.វ.ត.ក ដល់ប្រជាជនសាមញ្ញនៅទូទាំងប្រទេស និងជួយជ្រោមជ្រែងដល់ជនរងគ្រោះចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការ ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងមុខតំណែងនេះ លោកបានធ្វើការដោយផ្ទាល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីផ្តល់សិទ្ធិអំណាចឲ្យពួកគាត់ និង សម្រួលការចូលរួមរបស់ពួកគេឲ្យយល់ដឹងកាន់តែច្បាស់អំពីដំណើរការជម្រះក្តី និងផ្តល់ព័ត៌មានជាទៀងទាត់ដល់ពួកគេអំពីវិវឌ្ឍភាពសំខាន់ៗនៃការជម្រះក្តីផងដែរ។ ជារួមមកគោលដៅរបស់លោកនិងរបស់សមាគមអាដហុក គឺដើម្បីធានាឲ្យមានការចូលរួមដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយន័យ នៅក្នុងសាលាក្តីខ្មែរក្រហម។

**លោកស្រី LOBWEIN Wendy** គឺជាប្រធានអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) នៅផ្នែកគ្រប់គ្រងតុលាការ (CMS) នៃអ.វ.ត.ក។ មុនពេលតែងតាំង លោកស្រី Lobwein បានបំរើការនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) អស់រយៈពេល ៧ឆ្នាំ ជាទីដែលលោកស្រីបានបំរើការជាប្រធានស្តីទី និងជាអនុប្រធានផ្នែកគាំពារជនរងគ្រោះ និងសាក្សី (VWS) ហើយទទួលខុសត្រូវគ្រប់គ្រងការគាំពារសាក្សី ការការពារ និងសេវាកម្មប្រតិបត្តិការផ្សេងៗ។ មុនពេលបំរើការនៅតុលាការ ICTY លោកស្រីក៏បានធ្វើការមួយចំនួនដោយផ្តោតលើការរៀបចំជាបឋមលើការកម្មវិធីអភិវឌ្ឍន៍ ការគ្រប់គ្រង និងការផ្តល់សេវាកម្មសុខភាព និងសុខមាលភាព ជាពិសេសឯកទេសខាងសេវាកម្មស្តារនីតិសម្បទាសម្រាប់អ្នករស់រានមានជីវិតពីការរំលោភបំពានផ្លូវភេទ និងបន្ទាប់មកជាមួយអ្នករស់រានមានជីវិតនៃអំពើទារុណកម្មនិងការប៉ះទង្គិចផ្លូវចិត្តដែលបានមកនៅប្រទេសអូស្ត្រាលីជាជនភៀសខ្លួន។ លោកស្រីធ្លាប់បានទទួលខុសត្រូវសម្រាប់ការផ្តល់កម្មវិធីបណ្តុះបណ្តាលជាតិ និងអន្តរជាតិស្តីពីការយល់ដឹងផលប៉ះពាល់នៃអំពើរំលោភ អំពើទារុណកម្ម និងការប៉ះពាល់ទង្គិចផ្លូវចិត្តដោយសារសង្គ្រាម និងបានបង្រៀននៅនាយកដ្ឋានចិត្តសាស្ត្រនៃសាកលវិទ្យាល័យ Victoria ក្នុងការប្រឹក្សាយោបល់វប្បធម៌ចម្រុះ។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកកិច្ចការសង្គម នៅសាកលវិទ្យាល័យ Queensland ប្រទេសអូស្ត្រាលីក្នុងឆ្នាំ១៩៨២។

**លោកស្រី លី វិច្ឆតា** ជានាយិកា នៃអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និង ស្ត្រី (LSCW)។ អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រីជាអង្គការមិនគិតកំរៃ មិនមែននយោបាយ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០២ ដែលមានបេសកកម្មរបស់ខ្លួនដើម្បីរួមចំណែកដល់ការកសាងនីតិរដ្ឋ ការលើកកម្ពស់សិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងការពារសិទ្ធិមនុស្ស។ លោកស្រី លី ជាគ្រូបង្រៀនក្រៅម៉ោងលើការសិក្សាយេនឌ័រ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។ ក្នុងឆ្នាំ២០០៩ លោកស្រី បានត្រូវអញ្ជើញឲ្យធ្វើជាសាក្សីជំនាញនៅតុលាការស្ត្រី ក្រុងបាលី (Bali) ប្រទេសឥណ្ឌូនេស៊ី។ ក្នុងឆ្នាំ២០១១ លោកស្រីបានត្រូវអញ្ជើញឲ្យធ្វើជាវាគ្មិនសម្រាប់ព្រឹត្តិការណ៍សវនាការស្ត្រីលើកទី១ នៅរាជធានីភ្នំពេញ។ លោកស្រីទទួលបានសញ្ញាប័ត្រច្បាប់ក្នុងឆ្នាំ១៩៩៨ និងមុននេះទៀត ទទួលបានសញ្ញាប័ត្របរិញ្ញាប័ត្រ

(ឆ្នាំ១៩៩២) និងសញ្ញាប័ត្រអនុបណ្ឌិតគីមីវិទ្យា (ឆ្នាំ១៩៩៤) នៅប្រទេសកាណាដា។

**លោកស្រីបណ្ឌិត McGREW Laura** ជាអ្នកអនុវត្ត/អ្នកស្រាវជ្រាវ ដែលមានសញ្ញាប័ត្របណ្ឌិតមកពីមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវសន្តិភាពនិងការផ្សះផ្សារបស់សាកលវិទ្យាល័យ Coventry នៃចក្រភពអង់គ្លេស ។ សារណាបណ្ឌិតរបស់លោកស្រីមានចំណងជើងថា *“ការផ្សះផ្សាក្នុងប្រទេសកម្ពុជា: ការរស់នៅរួមគ្នា និងការរស់នៅបែកគ្នា”*។ លោកស្រីបានទទួលសញ្ញាប័ត្រអនុបណ្ឌិតមកពីសាលាសិក្សាអន្តរជាតិឈានមុខរបស់សាកលវិទ្យាល័យ Johns Hopkins និងសាកលវិទ្យាល័យ Emory។ លោកស្រី **Laura** បានធ្វើការជាមួយអង្គការសហប្រជាជាតិនិងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនក្នុងប្រទេសកម្ពុជា ព្រំដែនកម្ពុជា-ថៃ ប៊ូស្នី រ៉្វាន់ដា ស្រីលង្កា អាហ្វហ្កានីស្ថាន នេប៉ាល់ អាហ្វ្រិកខាងលិច និងសហរដ្ឋអាមេរិក ក្នុងវិស័យសិទ្ធិមនុស្ស នីតិរដ្ឋ ការលើកកម្ពស់ការរួមរស់ជាមួយគ្នា ការរៀបចំគម្រោងការស្រាវជ្រាវ ការតាមដាន និងការវាយតម្លៃ។ លោកស្រីក៏ជាអ្នកនិពន្ធអត្ថបទជាច្រើន ស្តីអំពី យុត្តិធម៌អន្តរកាលកម្ពុជា អភិបាលកិច្ចនិងការកសាងសន្តិភាព ផងដែរ។

**លោក MEISENBER Simon** គឺជាទីប្រឹក្សាច្បាប់ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ពីខែវិច្ឆិកា ឆ្នាំ២០១១ តាមរយតាមរយៈការបង្កើត និងគាំទ្រថវិការដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍និងទេសន្តរប្រវេសន៍អន្តរជាតិ (CIM) (អង្គការជួយផ្តល់ ធនធានមនុស្សសម្រាប់កិច្ចសហការអភិវឌ្ឍន៍អាល្លឺម៉ង់)។ មុនពេលចូលកាន់មុខតំណែងនេះ នៅដើមឆ្នាំ២០០៥ លោកគឺជា មន្ត្រីច្បាប់ជាន់ខ្ពស់នៅតុលាការពិសេសសម្រាប់សេរ៉ាឡេអូន ជាតំណែងដែលលោកបានធ្វើកាលពីឆ្នាំ២០០៣ម្តងរួចហើយ។ មុននេះទៀត លោកបានបំរើការក្នុងមុខតំណែងខុសៗគ្នា នៅក្នុងក្រុមការពារក្តីនៅតុលាការអន្តរជាតិសម្រាប់ប្រទេសអតីត យូហ្គោស្លាវី និង នៅអង្គជំនុំជម្រះនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា។ លោក ធ្លាប់ធ្វើការនៅវិទ្យាស្ថាន សម្រាប់ច្បាប់អន្តរជាតិស្តីពីសន្តិភាពនិងជម្លោះប្រដាប់អាវុធនៅសាកលវិទ្យាល័យ Ruhr ក្រុង Bochum ប្រទេសអាល្លឺម៉ង់។ លោក បានសិក្សាច្បាប់នៅប្រទេសអាល្លឺម៉ង់ និង ប្រទេសស្វីស។ លោកបានសរសេរបោះពុម្ពផ្សាយអត្ថបទជាច្រើន ក្នុងវិស័យ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងជាសហអ្នកបោះពុម្ពផ្សាយរបាយការណ៍ច្បាប់របស់តុលាការពិសេសសម្រាប់សេរ៉ាឡេអូន (Brilll Publisher)។

**លោក ម៉ុង មុន្នីចរិយា** (កម្ពុជា) គឺជាចៅក្រមនៅអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោកជាប្រធានចៅក្រមនៅសាលាដំបូងខេត្តព្រះសីហនុចាប់តាំងពីឆ្នាំ២០០៩។ លោក ត្រូវបានតែងតាំងជា ចៅក្រមតុលាការ កំពូលក្នុងឆ្នាំ២០០២ និងបំរើការជាចៅក្រមនៅសាលាដំបូងរាជធានីភ្នំពេញតាំងពីឆ្នាំ១៩៩៦។ ក្នុងឆ្នាំ១៩៩៤ លោក គឺជា ចៅក្រមកម្មសិក្សានៅក្រសួងយុត្តិធម៌។ លោកជាសមាជិកគណៈកម្មាធិការរៀបចំសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រម នីតិវិធីរដ្ឋប្បវេណីចាប់ពីឆ្នាំ១៩៩៩។ ចាប់ពីឆ្នាំ២០០៤ លោក គឺជាសាស្ត្រចារ្យច្បាប់នៅសាលាភូមិន្ទចៅក្រម និងមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ លោក គឺជានិស្សិតស្រាវជ្រាវថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យបៀលប្រាយ។ នៅឆ្នាំ១៩៩៣ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតច្បាប់ពីសាកលវិទ្យាល័យជាតិកាហ្សាក់ស្ថាន នៅសាធារណរដ្ឋកាហ្សាក់ស្ថាន (រដ្ឋអតីត សហភាពសូវៀត)។ ក្នុងឆ្នាំ១៩៩៥ លោក បានទទួលវិញ្ញាបនប័ត្រវិជ្ជាជីវៈចៅក្រម។ លោក បានបំរើការជាចៅក្រមកម្មសិក្សា នៅក្រសួងយុត្តិធម៌អស់រយៈពេល២ឆ្នាំ ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញអស់រយៈពេល៧ឆ្នាំ ជាចៅក្រមតុលាការកំពូល អស់រយៈពេល៧ឆ្នាំ និងជាប្រធានចៅក្រមសាលាដំបូងខេត្តព្រះសីហនុអស់រយៈពេល៦ខែ។ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៥ លោក បានចូលរួមវគ្គបណ្តុះបណ្តាលរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) នៅសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា។ ក្នុងឆ្នាំ២០០២ លោក បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលរៀបចំ ឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រីសហការជាមួយមជ្ឈមណ្ឌលសម្រាប់យុត្តិធម៌តាមបែបស្តារឡើងវិញនៅអាស៊ី (Centre for Restorative Justice in Cambodia)។

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**លោកវេជ្ជបណ្ឌិត មុន្នី សុត្ថារា** គឺជាសាស្ត្រាចារ្យ វេជ្ជបណ្ឌិតចិត្តវិកល និងប្រធានផ្នែកព្យាបាលជំងឺចិត្តវិកល នៅមន្ទីរពេទ្យព្រះកុសមៈ រាជធានីភ្នំពេញ។ លោក គឺបម្រើការងារជាវេជ្ជបណ្ឌិតចិត្តវិកល អស់រយៈពេលជាង១៤ឆ្នាំ។ លោក គឺជា សាស្ត្រាចារ្យនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ហើយបច្ចុប្បន្នជាទីប្រឹក្សាបច្ចេកទេសនៅអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) ។

**លោកបណ្ឌិត NJIKAM Ousman** បច្ចុប្បន្នបំរើការជាមន្ត្រីច្បាប់នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី (ICTY)។ មុនចូលរួមក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ លោកបានបំរើការនៅអង្គភាពអយ្យការនៃការិយាល័យព្រះរាជអាជ្ញានៅ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ(ICC)។ លោក ធ្លាប់ជាជំនួយការស្រាវជ្រាវអោយសាស្ត្រាចារ្យ Kai Ambos នៅសាកលវិទ្យាល័យ Gottingen ប្រទេសអាល្លឺម៉ង់។ លោក ទទួលបានសញ្ញាប័ត្របណ្ឌិតច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅសាកលវិទ្យាល័យ Gottingen ប្រទេសអាល្លឺម៉ង់ និងបានសរសេរនិងបោះពុម្ពផ្សាយអត្ថបទជាច្រើនទាក់ទងនឹងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតទស្សនៈវិជ្ជាច្បាប់ ពីសាកលវិទ្យាល័យ Yaoundre II ប្រទេសកាមេរូន និងសញ្ញាប័ត្រអនុបណ្ឌិតច្បាប់ ឧក្រិដ្ឋកម្មអន្តរជាតិ ពីសាកលវិទ្យាល័យ Teramo ប្រទេសអ៊ីតាលី បន្ថែមលើសញ្ញាប័ត្រអនុបណ្ឌិតច្បាប់ពីសាលកវិទ្យាល័យ Gottingen ប្រទេសអាល្លឺម៉ង់។ លោក គឺអ្នកសម្រុះសម្រួល និងទទួលបានការបណ្តុះបណ្តាលជាន់ខ្ពស់ ខាងដំណោះ ស្រាយជម្លោះនៅសាលាច្បាប់នៃសាកលវិទ្យាល័យ Tulane និង វិទ្យាស្ថាន für Anwaltsrecht an der Humboldt-Universität zu Berlin ប្រទេសអាល្លឺម៉ង់។

**លោក អ៊ឹង ហ្សឺឌី** បានបំរើការជាមន្ត្រីកម្មវិធីនៅលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារ សិទ្ធិមនុស្សកម្ពុជា (CHRAC) ចាប់ពីពាក់កណ្តាលឆ្នាំ២០០៥។ ក្នុងមុខតំណែងនេះ លោកទទួលខុសត្រូវលើការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយ និងកេរដំណែលរបស់សាលាក្តីខ្មែរក្រហម។ លោកធ្វើការសហការយ៉ាងសកម្មជាមួយដៃគូជាតិនិង អន្តរជាតិ ក៏ដូចជាអង្គភាពនានារបស់សាលាក្តី (ដូចជាផ្នែកកិច្ចការសាធារណៈ និងអង្គភាពគាំពារជនរងគ្រោះ) លើផ្នែកកំណែទម្រង់ច្បាប់ និងកំណែទម្រង់ប្រព័ន្ធតុលាការ។ មុនចូលបម្រើការងារនៅ CHRAC លោក ធ្លាប់ធ្វើការនៅអង្គការមូលនិធិអាស៊ី គណៈកម្មាធិការខុមប្រែល និងអង្គការសិទ្ធិមនុស្សក្នុងស្រុកមួយចំនួនទៀត។ លោក ទទួលសញ្ញាប័ត្រ អនុបណ្ឌិតផ្នែកទំនាក់ទំនងអន្តរជាតិ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងសញ្ញាប័ត្រនីតិសាស្ត្រ ពីសាកលវិទ្យាល័យ ភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោក ជាអ្នកតំណាងគណៈកម្មាធិការប្រព្រឹត្តិកម្ម ក្នុងការរៀបចំសន្និសីទស្តីពីកេរដំណែលនេះ។

**លោក អ៊ូ វីរៈ** គឺជាប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ។ ក្នុងឆ្នាំ២០០៧ លោកទទួលបានរង្វាន់សិទ្ធិមនុស្ស រីប៊ុក (Reebok Human Rights Award) លើយុទ្ធនាការសង្គមស៊ីវិលសម្រាប់សេរីភាពបញ្ចេញមតិ និងការនាំឲ្យមានការដោះលែង អ្នកតស៊ូមតិសិទ្ធិមនុស្ស ដែលត្រូវបានឃុំខ្លួនដោយសារការចោទប្រកាន់ថាបានរិះគន់រដ្ឋាភិបាលកម្ពុជា។ លោក ធ្លាប់ត្រូវបាន តែងតាំងសម្រាប់រង្វាន់សេរីភាព ចនហ៍ ហ៊ិមហ្វ្រី (John Humphrey Freedom Award)។ លោក ដឹកនាំសម្ព័ន្ធសម្រាប់សេរីភាព បញ្ចេញមតិក្នុងប្រទេសកម្ពុជា (AFEC) ដែលកំពុងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ដើម្បីលើកស្ទួយ និងការពារសេរីភាពបញ្ចេញមតិ ព័ត៌មាន និងការប្រមូលផ្តុំក្នុងប្រទេសកម្ពុជា។ លោក គឺជាអនុប្រធាន ក្រុមការងារអង្គការ មិនមែនរដ្ឋាភិបាលកម្ពុជាសម្រាប់ការបង្កើតគណៈកម្មការសិទ្ធិមនុស្សជាតិ និងស្ថាប័នសិទ្ធិមនុស្សអាស៊ី។

**លោក ពេជ អង្គ** ជាសហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតច្បាប់ ឯកទេសច្បាប់ឯកជននិងច្បាប់សិទ្ធិមនុស្ស និងសញ្ញាប័ត្របរិញ្ញាប័ត្រពីទីក្រុងលីយ៉ុង ប្រទេសបារាំង។ មុនពេលត្រូវបានតែងតាំងក្នុងមុខតំណែងបច្ចុប្បន្ន លោក គឺជាសាស្ត្រាចារ្យនៅសាកល វិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យបៀលប្រាយ។ លោកក៏ជាមេធាវីនៅការិយាល័យកម្ពុជា និងជាជំនួយការច្បាប់នៅក្រសួងកិច្ចការនារី។

## ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**លោក RAPP Stephen** ជាឯកអគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិក ទទួលបន្ទុកគ្រប់គ្រងការិយាល័យ យុត្តិធម៌ព្រហ្មទណ្ឌសកលនៅក្រសួងការបរទេសសហរដ្ឋអាមេរិក។ លោកបានត្រូវបានតែងតាំងដោយលោកប្រធានាធិបតី អូបាម៉ា និងទទួលតំណែងនេះក្នុងខែកញ្ញា ឆ្នាំ២០០៩។ មុនតួនាទីនេះ លោក គឺជាព្រះរាជអាជ្ញានៅតុលាការពិសេសសម្រាប់ ប្រទេសសេរ៉ាឡេអូន (២០០៧-២០០៩) ទទួលខុសត្រូវក្នុងការដឹកនាំការកាត់ទោសប្រធានាធិបតីលីប៊ី លោក Charles Taylor និងមនុស្សដទៃទៀត ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់អំពើឃោរឃៅដែលបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាម ស៊ីវិលនៅប្រទេសសេរ៉ាឡេអូន។ មុនមុខតំណែងនេះទៀត ឯកអគ្គរដ្ឋទូត Rapp បានបំរើការជាស្នាក្តីជាន់ខ្ពស់ និងជាប្រធាន អយ្យការនៅតុលាការព្រហ្មទណ្ឌ អន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (២០០១-២០០៧)។ ឯកអគ្គរដ្ឋទូត Rapp គឺជាមេធាវី នៅ Northern District of Iowa សហរដ្ឋអាមេរិក (១៩៩៣-២០០១) ក្នុងនាមជាមេធាវីឯកជន និងបម្រើការជាប្រធានបុគ្គលិក នៅអនុគណៈកម្មាធិការយុត្តាធិការព្រឹទ្ធសភា លើបទល្មើសអនីតជន ហើយលោកក៏ជា ជាសមាជិកដែលបានជាប់ឆ្នោតនៅអង្គភាព នីតិបញ្ញត្ត Iowa សហរដ្ឋអាមេរិក។

**លោកស្រី REIGER Caitlin** គឺជាមេធាវីអូស្ត្រាលី ធ្វើការងារលើវិស័យយុត្តិធម៌អន្តរកាល និងនីតិរដ្ឋក្រោយជម្លោះ ឯកទេសផ្តោតលើតុលាការចម្រុះ អស់រយៈពេលជាងមួយទសវត្សរ៍មកហើយ។ ក្នុងឆ្នាំ២០០១-២០០២ លោកស្រីបាន សហការបង្កើត កម្មវិធីឃ្លាំមើលប្រព័ន្ធតុលាការនៅប្រទេសទីម័រខាងកើត។ ឆ្នាំ២០០៣-២០០៥ លោកស្រី គឺជាមន្ត្រីច្បាប់ជាន់ខ្ពស់របស់ចៅក្រម នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន។ រយៈពេល ៧ឆ្នាំចុងក្រោយនេះ លោកស្រី ធ្វើការនៅមជ្ឈមណ្ឌលអន្តរជាតិ សម្រាប់យុត្តិធម៌អន្តរកាលដោយសង្កេតលើព្រឹត្តិការនៅកម្ពុជា លោកស្រី ក៏ជាអ្នកដឹកនាំការចូលរួមគោលនយោបាយអន្តរជាតិ ឲ្យមជ្ឈមណ្ឌលដែរ។ បច្ចុប្បន្ន លោកស្រីគឺអ្នកប្រឹក្សាយោបល់ឯករាជ្យនៅរាជធានីភ្នំពេញ។

**លោក RIAD Hady** គឺជាអ្នកប្រឹក្សាយោបល់និងជាប្រធានផ្នែកអភិវឌ្ឍន៍នៅស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នៅរាជធានីភ្នំពេញ លោកកាន់មុខតំណែងដែលលោកបានចូលកាន់ចាប់ពីឆ្នាំ២០០៩។ ឆ្នាំ២០០៥-២០០៩ លោកគឺជាអនុប្រធាន អង្គភាពសម្រាប់ធានាគារអភិវឌ្ឍន៍តំបន់ និងIFAD នៅក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហព័ន្ធអាល្លឺម៉ង់ (BMZ)។ ឆ្នាំ២០០១-២០០៥ លោកជាប្រធានផ្នែកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅស្ថានទូតអាល្លឺម៉ង់ នៅក្រុង Dar es Salam ប្រទេសតង់ហ្សានី។ លោកបានចូលបំរើការនៅBMZក្នុងឆ្នាំ១៩៩១ និងបានបម្រើការនៅអង្គភាពនានា ដោយផ្តោត លើបណ្តារដ្ឋនៅទ្វីបអាហ្វ្រិក និងមជ្ឈឹមបូព៌ា តាំងពីពេលនោះមក។ ក្នុងឆ្នាំ១៩៩៧ លោក Raid គឺជាលេខធិការទីពីរនៅ បេសកកម្មអចិន្ត្រៃយ៍អាល្លឺម៉ង់នៅអង្គការសហប្រជាជាតិ។

**ឯកឧត្តម រោង ឈង** គឺជាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងជាប្រធានផ្នែកគាំពារជនរងគ្រោះ(VSS) នៅអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា (អ.វ.ត.ក)។ មុនពេលចូលបម្រើការនៅ អ.វ.ត.ក ឯកឧត្តម គឺជាអនុប្រធាន និងជាអគ្គលេខាធិការនៃ គណៈកម្មាធិការជាតិសម្រាប់ប្រជាពលរដ្ឋនិងអភិវឌ្ឍន៍ និងជានាយកប្រតិបត្តិនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ។ ឯកឧត្តម ធ្លាប់បង្រៀនមុខវិជ្ជា គ្រប់គ្រងធនធានមនុស្ស ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង នៅតាមសាកលវិទ្យាល័យជាច្រើន នៅរាជធានីភ្នំពេញ។ ឯកឧត្តម រោង ឈង ទទួលបានបរិញ្ញាប័ត្រអប់រំផ្នែកគណិតវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសញ្ញាប័ត្រអនុបណ្ឌិតទំនាក់ទំនងឧស្សាហ៍កម្ម ជំនាញខាងអភិវឌ្ឍន៍ធនធានមនុស្ស ពីសាកលវិទ្យាល័យហ្វីលីពីន។ លោក ក៏ទទួលបានសញ្ញាប័ត្របណ្ឌិតរដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យហ្វីលីពីនផងដែរ។

**លោក SCHEFFER David** ជាឯកអគ្គរដ្ឋទូត គឺជាអ្នកជំនាញការពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លើជំនួយ អង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហម។ លោក គឺជាសាស្ត្រាចារ្យច្បាប់ និងជានាយកមជ្ឈមណ្ឌលសិទ្ធិមនុស្ស អន្តរជាតិ មហាវិទ្យាល័យ ច្បាប់ នៅសាកលវិទ្យាល័យ Northwestern ក្រុងឈីកាហ្គោ (Chicago)។ លោក គឺជាឯកអគ្គរដ្ឋទូតគោចរទីមួយសម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម (១៩៩៧-២០០១) និងបានដឹកនាំគំនិតផ្តួចផ្តើមរបស់អាមេរិកក្នុង ការបង្កើតតុលាការឧក្រិដ្ឋកម្មសង្គ្រាមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ក្នុងចំណោមបេក្ខជនដទៃ លោកបានត្រូវជ្រើសតាំងដោយ ទស្សនាវដ្តី គោលនយោបាយបរទេស ជា "អ្នករិះគិត

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សកលជាខ្ពស់ប្រចាំឆ្នាំ២០១១" (Top Global Thinker of 2011) និងជាអ្នកនិពន្ធសៀវភៅ "All the Missing Souls: A Personal History of the War Crimes Tribunals" (Princeton University Press, 2012) និយាយពីបទពិសោធន៍អ្នកខាងក្នុងចំពោះល្បែងអន្តរជាតិក្នុងការកាត់ទោសអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសាហាវឃោរឃៅ។ លោក បានសរសេរ និងបោះពុម្ពផ្សាយយ៉ាងទូលំទូលាយស្តីអំពីច្បាប់អន្តរជាតិ និងនយោបាយ ។

**លោកស្រី សេក ស៊ីសុខុម** បម្រើការនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញចាប់ពីឆ្នាំ១៩៨៧ ក្នុងតួនាទីដំបូងជាអនុប្រធាន នាយកដ្ឋានគរុកុសល្យចិត្តវិទ្យាហើយបានត្រូវតម្លើងឋានៈទៅជាប្រធាននាយកដ្ឋានចិត្តវិទ្យាក្នុងឆ្នាំ២០០៩។ លោកស្រី ទទួល បានសញ្ញាប័ត្រអនុបណ្ឌិតការគ្រប់គ្រងអប់រំពីសាកលវិទ្យាល័យ Sofia ប្រទេសប៊ុលការី ( ១៩៨៧ ) និង សញ្ញាប័ត្រអនុបណ្ឌិត អប់រំចិត្តវិទ្យានៅសាកលវិទ្យាល័យ Brussels ប្រទេសប៊ែលហ្សិក( ១៩៩៦ )។

**លោកបណ្ឌិត SELMICI Andreas** កើតនៅឆ្នាំ១៩៦៣ នៅប្រទេសស្វីស បូជាវិជ្ជាជីវៈរបស់លោកចំពោះការគាំទ្រជនរងគ្រោះនៃ អំពើរំលោភបំពានសិទ្ធិមនុស្ស។ ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១១ លោក បានសម្របសម្រួលកម្មវិធីរបស់សេវាកម្មអភិវឌ្ឍន៍ អាល្លឺម៉ង់(GIZ) ដែលមានឈ្មោះថា *"យុត្តិធម៌ និងការផ្សះផ្សាក្នុងប្រទេសកម្ពុជា"*។ កម្មវិធីនេះគាំទ្រដល់ការចូលរួមរបស់ជន រងគ្រោះនៅសាលាក្តីខ្មែរក្រហម។ បច្ចុប្បន្ន លោកគឺជាអ្នកគ្រប់គ្រងគម្រោង *"សិទ្ធិទទួលបានយុត្តិធម៌សម្រាប់ស្ត្រី"* ដែលជាការ សហការនៃសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ (GIZ) ជាមួយក្រសួងកិច្ចការនារីប្រទេសកម្ពុជា។

**លោកស្រី SIMMONEAU-FORT Elisabeth** គឺជាសហមេធាវីនាំមុខអន្តរជាតិ តំណាងឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុង សំណុំរឿង០០២ ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោកស្រី បានទទួលសញ្ញាប័ត្រច្បាប់ពីសាកល វិទ្យាល័យប៉ារីស II Assas and X Nanterre ។ លោកស្រី មានបទពិសោធន៍ជាមេធាវីអស់រយៈពេលជាង៣០ឆ្នាំនៅម៉ុងប៉េលីយេ ប្រទេសបារាំង។ លោកស្រី បានបូជាពេលវេលាក្នុងវិជ្ជាជីវៈរបស់លោកស្រីដើម្បីការពារសិទ្ធិជនរងគ្រោះនៅតុលាការឧក្រិដ្ឋកម្ម ដោយផ្តោតជាពិសេសទៅលើសិទ្ធិស្ត្រី និងកុមារ។ លោកស្រី គឺជាអ្នកចូលរួនបង្កើតសមាគម "មេធាវីនិងកុមារ" (l' Avocat et l' Enfant) ហើយ លោកស្រី ជាសមាជិកក្រុមមេធាវីស្ម័គ្រចិត្តដែលជួយដល់អនីតិជនឧក្រិដ្ឋជន។

**លោកបណ្ឌិត ស៊ីន រិទ្ធ** គឺជាចៅក្រមនៅអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោក បានសិក្សាច្បាប់អស់រយៈពេល១០ឆ្នាំនៅសាកលវិទ្យាល័យជាតិកាហ្សាក់ស្ថាន និងទទួលបានសញ្ញាប័ត្របណ្ឌិតច្បាប់ពីសាកល វិទ្យាល័យជាតិកាហ្សាក់ស្ថានក្នុងឆ្នាំ១៩៩៧។ លោក បានចាប់ផ្តើមបំរើការជាមន្ត្រីច្បាប់នៅក្រសួងយុត្តិធម៌ក្នុងឆ្នាំ១៩៩៨។ ក្នុងឆ្នាំ២០០១ លោក ទទួលបានការតែងតាំងជាព្រះរាជអាជ្ញារងនៅតុលាការខេត្តបាត់ដំបង និងនៅក្នុងឆ្នាំ២០០៥ លោកទទួលបានការតែងតាំងជាអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ លោកចៅក្រម បានបំរើការជាសមាជិកគណៈកម្មាធិការ រៀបចំសេចក្តីព្រាងក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់ប្រទេសកម្ពុជា។ លោក ជាសាស្ត្រាចារ្យឧក្រិដ្ឋវិទ្យា និងច្បាប់ ព្រហ្មទណ្ឌអន្តរជាតិនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**លោក សូ មូស្សេទ្ធី** បានស្បថចូលជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែធ្នូ ឆ្នាំ២០០៣។ ចាប់ពីពេលនោះមក លោកបានការពាតកូនក្តីក្រីក្រជាច្រើនក្នុងសំណុំរឿងព្រហ្មទណ្ឌ និងបណ្តឹងស៊ីវិល។ មុននេះ លោកបានបំរើការនៅមជ្ឍមណ្ឌល អភិវឌ្ឍន៍សង្គម (CSD) ដែលជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្នុងតួនាទីជាអនុប្រធានគម្រោងឃ្លាំមើលតុលាការ។ លោកទទួលសញ្ញាប័ត្រអនុបណ្ឌិតច្បាប់នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅឆ្នាំ២០១០។ លោក បានចូលរួមក្នុងក្រុមការពារក្តីរបស់ លោក **អៀង សារី** ជាអ្នកគ្រប់គ្រង

## ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងក្នុងឆ្នាំ២០០៧។

**លោក សុក សំអឿន** គឺជានាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា (CDP) ។ លោក បានបម្រើការនៅអង្គការតាំងពីឆ្នាំ១៩៩៥។ ក្រោមការដឹកនាំរបស់លោក អង្គការ CDP បានទទួលពានរង្វាន់អន្តរជាតិ ស្តីពីសិទ្ធិមនុស្ស ពីគណៈមេធាវី អាមេរិក។ លោកជាប្រឹក្សាភិបាលនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាជាច្រើន។ លោក បានរៀបចំសិក្ខាសាលាជាច្រើនពាក់ព័ន្ធ កំណែទម្រង់រដ្ឋបាលយុត្តិធម៌នៅប្រទេសកម្ពុជា និងវគ្គបណ្តុះបណ្តាលជាច្រើនសម្រាប់ប៉ូលីស មន្ត្រីរដ្ឋាភិបាល និងសង្គមស៊ីវិល។ លោក គឺជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យជាច្រើន មានដូចជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា(PUC) និងសាកលវិទ្យាល័យខេមរៈ។ លោកក៏បានសរសេរ និងបោះពុម្ពផ្សាយ សៀវភៅជាច្រើនស្តីពីបញ្ហាទាក់ទងសិទ្ធិមនុស្ស មានដូចជា ការជួញដូរមនុស្ស ការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យនៅប្រទេស កម្ពុជា និងបច្ចេកទេសស៊ើបអង្កេតព្រហ្មទណ្ឌ។ លោក ទទួលបានអាហារូបករណ៍ ឈីវ៉នីង ពីចក្រភពអង់គ្លេស (a British Chevening Fellow) ទៅសិក្សាជំនាញឯកទេសស្តីពីលទ្ធិប្រជាធិបតេយ្យនៅសាកលវិទ្យាល័យ Birmingham ក្នុងឆ្នាំ២០០៧។ លោកបានទទួលការបណ្តុះបណ្តាលស្តីពីកោសល្យវិច័យវេជ្ជសាស្ត្រ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រខូឡុមបូ (ប្រទេសស្រីលង្កា ក្នុងឆ្នាំ២០០២) ទទួលការបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សនៅអង្គការសហប្រជាជាតិ (ឆ្នាំ១៩៩២) និងនៅវិទ្យាស្ថាន សិទ្ធិមនុស្សដាណឺម៉ាក ក្នុងប្រទេសដាណឺម៉ាក (ឆ្នាំ២០០៥) និងបន្ថែមលើនេះ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែក ធុរកិច្ចនៅសាកលវិទ្យាល័យ Charles Sturt (ប្រទេសអូស្ត្រាលី) ក្នុងឆ្នាំ២០០៩។

**លោកបណ្ឌិត STEGMILLER Ignaz** បណ្ឌិតច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មកពីសាកលវិទ្យាល័យ Georg-August Gottingen ប្រទេសអាល្លឺម៉ង់។ និក្ខេបបទថ្នាក់បណ្ឌិតរបស់លោកផ្តោតលើ "ដំណាក់កាលមុនការស៊ើបអង្កេតរបស់តុលាការព្រហ្មទណ្ឌ អន្តរជាតិ"។ ក្នុងរយៈពេលនៃការស្រាវជ្រាវរបស់លោក លោក គឺជាអ្នកស្រាវជ្រាវទស្សនៈកិច្ចនៅសាកលវិទ្យាល័យយែល (Yale University) និងបានបំរើការជាអ្នកវិជ្ជាជីវៈទស្សនៈកិច្ច នៅផ្នែកប្រឹក្សាយោបល់ច្បាប់នៅការិយាល័យព្រះរាជអាជ្ញា នៃតុលាការព្រហ្មទណ្ឌ អន្តរជាតិ។ មុនពេលនេះ លោកបានបំរើការជាជំនួយការស្រាវជ្រាវសម្រាប់សាស្ត្រាចារ្យបណ្ឌិត Kai Ambos នៅសាកលវិទ្យាល័យ Gottingen ហើយលោកបានបោះពុម្ពផ្សាយអត្ថបទជាច្រើនក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ លោក បានសិក្សាច្បាប់នៅ សាកលវិទ្យាល័យ GieBen (Justus-Liebig University) នៅទីក្រុងប៉ារីស (University X-Nanterre) និងនៅទីក្រុង Berlin (Humboldt University) ព្រមទាំងនៅ Gottingen (Georg-August University, doctoral degree) និង នៅ Bremen (Referendariat)។ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១១ លោកគឺជាទីប្រឹក្សាសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់(GIZ) ប្រចាំគណៈកម្មាធិការ ប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)។ ក្នុងតួនាទីរបស់លោកនៅគណៈកម្មាធិការប្រព្រឹត្តិកម្ម លោក បាននាំឲ្យមានការផ្តួចផ្តើមគំនិតជុំវិញ កេរដំណែលសាលាក្តីខ្មែរក្រហម ដូចជាការរចនា និងការរៀបចំផែនការ សន្និសីទស្តីពីកេរដំណែលនេះ។

**លោកស្រី STRASSER Judith** គឺជាអ្នកចិត្តសាស្ត្រ ហើយបច្ចុប្បន្នបំរើការនៅអង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO Cambodia)។ ក្នុងឋានៈជាទីប្រឹក្សាជាន់ខ្ពស់របស់សេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់(GIZ) កញ្ញា បង្កើតនិងគ្រប់គ្រងការអន្តរាគមន៍ខាងចិត្តសាស្ត្រ ដើម្បីដោះស្រាយបញ្ហាការប៉ះទង្គិចផ្លូវចិត្តក្រោយជម្លោះ និងដើម្បីគាំទ្រសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនៅសាលាក្តីខ្មែរក្រហម គាត់កាន់តួនាទីនេះចាប់ពីឆ្នាំ២០០៨មក។

**លោក សួន ប៊ុនស័ក្តិ** គឺជាលេខាធិការប្រតិបត្តិ នៃគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ចាប់ពីពាក់កណ្តាលឆ្នាំ២០០៦។ លោក ជាអ្នកទទួលខុសត្រូវចំបងលើការធ្វើរបាយការណ៍ទៅ គណៈកម្មាធិការគន្លឹះ របស់គណៈកម្មាធិការប្រព្រឹត្តិកម្ម និងមើលការខុសត្រូវលើការគ្រប់គ្រងការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការប្រព្រឹត្តិកម្ម និងបុគ្គលិកលេខាធិការដ្ឋាន។ គណៈកម្មាធិការប្រព្រឹត្តិកម្ម សម្របសម្រួលអង្គការសមាជិកចំនួន២១ នៅរាជធានីភ្នំពេញ និង គណៈកម្មាធិការប្រព្រឹត្តិកម្មខេត្ត (PACs)។

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកែទម្រង់នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

លោក មើលលើកម្មវិធីទាំងអស់របស់គណៈកម្មាធិការប្រព្រឹត្តិកម្ម ដែលរួមមានការ កសាងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធផ្សេងៗ ជាមួយម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធនានា។ លោក ទទួលបរិញ្ញាប័ត្រច្បាប់ពីសាកលវិទ្យាល័យន័រតុន រាជធានីភ្នំពេញ។ ចាប់តាំងពីប្រឡូក្នុងវិស័យការងារ ដែលចាប់ផ្តើមដំបូង ជាមួយ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា (UNTAC) ក្នុងតួនាទីជាមន្ត្រីរៀបចំការបោះឆ្នោតរបស់អង្គការ សហប្រជាជាតិ និងជាអ្នកបកប្រែ លោក ទទួលបានបទពិសោធន៍ការងារជាង១០ឆ្នាំ ក្នុងវិស័យសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ។ លោក ធ្លាប់ធ្វើការងារជាមួយអង្គការអន្តរជាតិនិងអង្គការក្នុងស្រុក។ បច្ចុប្បន្ន លោក កំពុងសិក្សាថ្នាក់អនុបណ្ឌិតរដ្ឋ បាលសាធារណៈ។

**លោក សួន វិសាល** គឺជាមេធាវីដែលផ្តល់អាជ្ញាបណ្ណឲ្យប្រកបវិជ្ជាជីវៈ និងជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ១៩៩៧។ លោក មានបទពិសោធន៍ជាង១៤ឆ្នាំក្នុងការការពារក្តីទាក់ទិននឹងសិទ្ធិមនុស្ស អាពាហ៍ពិពាហ៍និង គ្រួសារ ការជួញដូរ និងដីធ្លី។ លោក មានបទពិសោធន៍ច្រើនក្នុងការវិភាគច្បាប់ ធ្វើសេចក្តីព្រាងច្បាប់ និងការផ្តល់មតិយោបល់ ច្បាប់ និងការតស៊ូមតិផ្លូវច្បាប់។ លោក គឺជាម្ចាស់និងជាប្រធានការិយាល័យក្រុមមេធាវីខ្មែរអប្សរា ព្រមទាំងជាអគ្គលេខាធិការនៃ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ន។ ក្នុងឆ្នាំ២០០៩ លោកបានត្រូវតែងតាំងឲ្យបំរើការជាសមាជិកក្រុម ប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ជាកន្លែងដែលលោកផ្តល់យោបល់ច្បាប់ ធ្វើសេចក្តីព្រាងច្បាប់ និងត្រួតពិនិត្យមើលច្បាប់មុននឹងច្បាប់ទាំងនេះត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីដើម្បីឯកភាព។ ក្នុងឆ្នាំ២០០៧ លោក ជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់នៅអង្គការមូលនិធីអាស៊ី (The Asia Foundation)។ លោកក៏បានត្រូវបោះឆ្នោតឲ្យធ្វើជា ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរក្នុងឆ្នាំ២០០៤។ មុនការកាន់តំណែងទាំងនេះ លោកបានបម្រើការនៅ ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា(CDP) ជាប្រធានក្រុមមេធាវីអស់រយៈពេល១០ឆ្នាំ។ លោកបានសិក្សានៅសាលាច្បាប់ នៅសាកលវិទ្យាល័យសានហ្វ្រាន់ស៊ីស្កូ (San Francisco School of Law) នៅប្រទេសអាមេរិក និងត្រូវបានទទួលស្គាល់ជា គ្រូបង្រៀនច្បាប់ក្នុងឆ្នាំ១៩៩៥។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតច្បាប់ផ្នែកសិទ្ធិមនុស្សអន្តរជាតិពីសាកលវិទ្យាល័យ ហុងកុង(ឆ្នាំ២០០២)។ លើសពីនេះទៀត លោក ក៏ជាបេក្ខជនថ្នាក់បណ្ឌិតច្បាប់នៅសាកលវិទ្យាល័យឯកទេសកម្ពុជា (CUS) ផងដែរ។

**ឯកឧត្តម ស៊ុយ ម៉ុងលាង** គឺជាអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (តាំងពីឆ្នាំ២០០២)។ លោកបានទទួលបរិញ្ញាប័ត្រច្បាប់ផ្នែកនីតិសាធារណៈ ពីមហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្រ្តសេដ្ឋកិច្ច នៅរាជធានីភ្នំពេញ ក្នុងឆ្នាំ ១៩៧៤ សញ្ញាប័ត្របណ្ឌិតវិទ្យាសាស្រ្តនយោបាយនៅសាកលវិទ្យាល័យច្បាប់ទូលូ ប្រទេសបារាំងក្នុងឆ្នាំ១៩៧៥, សញ្ញាប័ត្រឧត្តមសិក្សាជាន់ខ្ពស់ផ្នែករដ្ឋបាលសហគ្រាសនៅ Insitute de preparation aux Affaires ទីក្រុងទូលូ ប្រទេសបារាំងក្នុងឆ្នាំ១៩៧៦ និង a D.E.A., Programme Doctoral de Gestion, Ecole suprérieure de commerce, Ecully, ទីក្រុងលីយ៉ុង ប្រទេសបារាំងក្នុងឆ្នាំ១៩៨៥។ ឯកឧត្តម គឺជាអនុរដ្ឋលេខាធិការនៃក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការ (ឆ្នាំ១៩៩៧-១៩៩៨)។ បច្ចុប្បន្ន លោកគឺជាសមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី (តាំងពីឆ្នាំ១៩៩៩)។

**លោក តាន់ វិសាល** ជាអ្នកគ្រប់គ្រងកម្មវិធីសំណងនិងវិធានការមិនមែនតុលាការ នៅផ្នែកគាំពារជនរងគ្រោះ នៃអ.វ.ត.ក។ មុនការចូលរួមក្នុងសាលាក្តីនេះ លោកបានបំរើការជាមន្ត្រីសេវាកម្មមូលដ្ឋាន និងជាប្រធានក្រុមថ្នាក់ខេត្ត នៅមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) ជាទីប្រឹក្សារដ្ឋបាលក្នុងស្រុក ជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP/PLG) ជាអ្នកសម្របសម្រួលកម្មវិធីថ្នាក់ខេត្តនិងជាអ្នកគ្រប់គ្រងគម្រោង (គម្រោងការកាត់បន្ថយគ្រោះធម្មជាតិ និងការត្រៀមរៀបចំផែនការសកម្មភាពជាមួយអង្គការ CARE ក្នុងប្រទេសកម្ពុជា) ជាអ្នកសម្របសម្រួលធនធានមនុស្ស និងជាអ្នកសម្របសម្រួលថាមពលជាមួយអង្គការអន្តរជាតិ CARE និងជាមន្ត្រីកម្មវិធីនិងអ្នកបណ្តុះបណ្តាល PACT។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងអភិវឌ្ឍន៍ និងសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកនីតិសាស្រ្ត មកពីសាកលវិទ្យាល័យន័រតុន រាជធានីភ្នំពេញ។

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**លោក TAYLOR David** ជាទីប្រឹក្សាស្រាវជ្រាវ និងគោលនយោបាយនៅអង្គការឃ្លាំមើលនិទណ្ឌភាពអន្តរជាតិ (NGO Impunity Watch) ដែលមានមូលដ្ឋាននៅប្រទេសហូឡង់។ បច្ចុប្បន្ន លោកក៏ជាបេក្ខជនបណ្ឌិតនៅសាកលវិទ្យាល័យ Maastricht នៅប្រទេសហូឡង់ដែរ។ នៅអង្គការឃ្លាំមើលនិទណ្ឌភាពអន្តរជាតិ លោកធ្វើការចំបងលើការស្រាវ ជ្រាវនូវប្រធានបទទាក់ទងនឹងការចងចាំបន្ទាប់ពីជម្លោះ និងលើការរៀបចំប្រទេស ដែលការស្រាវជ្រាវនេះធ្វើនៅប្រទេស Burundi។ លោកមានបទពិសោធន៍នៅប្រទេស Burundi និង Rwanda ហើយលោកក៏មានចំណាប់អារម្មណ៍លើយុត្តិធម៌អន្តរកាល ជាពិសេស ផ្តោតលើតម្រូវការនិងការរំពឹងទុកនៅថ្នាក់មូលដ្ឋាន ក្រោយពីអំពើហិង្សា និងការធានាវិធីសាស្ត្រពីថ្នាក់ក្រោមទៅលើ ចំពោះការដោះស្រាយជាមួយអតីតកាល។

**លោក ថោង សុជាតិ** ជាសមាជិកមួយរូបនៃគណៈគ្រប់គ្រងរដ្ឋបាលនៃអ.វ.ត.ក និងជាប្រធានផ្នែកថវិកា និងហិរញ្ញវត្ថុ (ផ្នែកកម្ពុជា) របស់អ.វ.ត.ក។ មុនពេលចូលបំរើការនៅអ.វ.ត.ក លោកបានកាន់តំណែងជាន់ខ្ពស់នៅក្នុងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ នៅទីស្តីការគណៈរដ្ឋមន្ត្រី, ក្រុមប្រឹក្សាកាត់រំសាយកងកំលាំងប្រដាប់អាវុធ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។ លើសពីនេះ លោកក៏ធ្លាប់ជា ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ភ័ស្តុភារ និងព័តមាន នៃអាជ្ញាធរកំចាត់មីន និងជួយជនរងគ្រោះដោយសារមីនកម្ពុជា និងធ្លាប់ជាទីប្រឹក្សានៅធនាគារពិភពលោកជាច្រើនឆ្នាំ។ លោកថោង សុជាតិ បានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រង ពីសាកលវិទ្យាល័យបៀលប្រាយ និងសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ចពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ បច្ចុប្បន្ន លោកក៏ជាបេក្ខជនថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ Western ផងដែរ។

**លោក ធន សារាយ** ជាប្រធានសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)។ លោកក៏ជាប្រធានសម្របសម្រួល នៃគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ជាសម្ព័ន្ធនៃសមាគមអង្គការមិនមែនរដ្ឋាភិបាលជាតិចំនួន២១ ដែលកំពុងធ្វើការក្នុងវិស័យ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ជាមួយនឹងសហការីរបស់លោកមួយចំនួន លោក **ធន សារាយ** បានសហការបង្កើតសមាគមអាដហុកដែលជាអង្គការសិទ្ធិមនុស្សលើកដំបូងក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩១ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពកម្ពុជាបានត្រូវសម្រេចនៅទីក្រុងប៉ារីស។ ក្រោមការដឹកនាំរបស់លោក សមាគមអាដហុក និងគណៈកម្មាធិការប្រព្រឹត្តិកម្ម បានចូលរួមចែកចំណែកជាវិជ្ជមានក្នុងការបង្កើនការយល់ដឹងពីបញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ សមាគមរបស់លោកជាសមាគមមួយក្នុងចំណោមសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួនសំខាន់ៗ ដែលបានជំរុញឲ្យមានការបង្កើតសាលាក្តីខ្មែរក្រហម ដែលមានលក្ខណៈជាតុលាការឯករាជ្យបង្កើតដើម្បីដោះស្រាយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលកើតឡើងក្នុងរបបខ្មែរក្រហម។ ដោយរួមជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិជាច្រើនផ្សេងៗទៀត លោកបានជំរុញឲ្យមានការទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងការចូលរួមយ៉ាងសកម្មក្នុងដំណើរការរបស់សាលាក្តីនេះ។ លោក **ធន សារាយ** ធ្លាប់បានទទួលរង្វាន់មេដាយផ្នែកសិទ្ធិមនុស្សមួយចំនួនពីអង្គការអន្តរជាតិមួយចំនួន សម្រាប់កិច្ចប្រឹងប្រែងដ៏អង់អាចរបស់លោកក្នុងការជួយលើកស្ទួយអ្នកការពារសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ន សមាគមអាដហុក គឺជាសមាជិកនៃអង្គការនានាប្រចាំតំបន់ ដូចជា សម្ព័ន្ធអន្តរជាតិដើម្បីការពារសិទ្ធិមនុស្ស (FIDH) ដែលមានមូលដ្ឋាននៅក្រុងប៉ារីស និងវេទិកាអាស៊ីសម្រាប់សិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (Forum-Asia) ដែលមានមូលដ្ឋាននៅទីក្រុងបាងកក ។

**លោកស្រី ទី ស្រ៊ីនណា** បច្ចុប្បន្នជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក។ លោកស្រី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ជំនាញនីតិអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌ។ លោកស្រីត្រូវបានចូលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០០៧។ មុនពេលបម្រើការនៅ អ.វ.ត.ក លោកស្រី ស្រ៊ីនណា ធ្លាប់បានបំរើការនៅអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) ការិយាល័យមេធាវី Pana Asean និងនៅក្រុមមេធាវីអន្តរជាតិ អាស៊ីប៉ាស៊ីហ្វិក (Asia Pacific International Law Firm)។

# ប្រវត្តិរូបសង្ខេបរបស់វាគ្មិនសន្និសីទ ស្តីពី ទស្សនៈចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**លោកស្រី WINTER Renate** ជាចៅក្រមនៅសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន ដែលបានតែងតាំងដោយអង្គការសហប្រជាជាតិ។ លោកស្រីគឺជាប្រធាន ចៅក្រមចាប់ពីឆ្នាំ២០០៨ដល់ឆ្នាំ២០០៩ និងបានបំរើការជាប្រធានស្តីទីចាប់ពីខែមីនាដល់ខែឧសភាឆ្នាំ២០០៤។ មុនការតែងតាំងរបស់លោកស្រីនៅតុលាការពិសេសសម្រាប់សេរ៉ាឡេអូន ឆ្នាំ២០០២ លោកស្រី Winter បានបំរើការជាចៅក្រមអន្តរជាតិ នៅតុលាការកំពូលកូសូវ៉ូ ជាផ្នែកនៃបេសកកម្មរដ្ឋបាលអង្គការសហប្រជាជាតិ។ លោកស្រី ជាអ្នកជំនាញច្បាប់គ្រួសារព្រមទាំងប្រព័ន្ធយុត្តិធម៌អនីតិជន បញ្ហាយុត្តិធម៌ស្ត្រី អំពើអនាចារ ពលរកម្មកុមារ និងតួនាទីសារព័ត៌មានក្នុងការតស៊ូមតិ។ ចាប់ពីឆ្នាំ១៩៨១ លោកស្រីធ្លាប់ជាចៅក្រមនៅតុលាការយុវជនវីយែន ជាកន្លែងដែលលោកស្រីបានធ្វើការងាលើគម្រោងជាច្រើន ដើម្បីជួយស្តានីតិសម្បទាយុវជនញៀនថ្នាំ និងពិការផ្លូវចិត្ត។ លោកស្រី Winter ក៏បានធ្វើការងារលើគម្រោងទាក់ទងនឹងយុវជននិងទាហ៊ានកុមារសម្រាប់អង្គការសហប្រជាជាតិ រួមមាននៅបណ្តាប្រទេសនៅទ្វីប អាហ្វ្រិកជាច្រើន។ លោកស្រី មានបទពិសោធន៍ទូលំទូលាយលើបញ្ហាច្បាប់ទាក់ទងឧក្រិដ្ឋកម្មដែលបានរៀបចំ និងការស្តារយុត្តិធម៌។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ មក លោកស្រី **Winter** បានធ្វើជាប្រធានសន្និសីទអន្តរជាតិជាច្រើនទាក់ទងរឿងយុត្តិធម៌អនីតិជន និងបញ្ហាយុត្តិធម៌យេនឌ័រ។ បច្ចុប្បន្ន លោកស្រីក៏ជាប្រធានសមាគមយុវជនអន្តរជាតិ និងជាចៅក្រមតុលាការគ្រួសារផងដែរ។

**ឯកឧត្តម យូ ប៊ុនឡេង** ជាសហចៅក្រមស៊ើបអង្កេតជាតិ នៅអ.វ.ត.ក ចាប់តាំងពីការចាប់ផ្តើមតុលាការនេះចាប់ផ្តើមដំណើរការមក។ ឯកឧត្តម ជាចៅក្រមសាលាឧទ្ធណ៍កម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ ហើយត្រូវបានតែងតាំងជាប្រធានសាលាឧទ្ធណ៍ក្នុងឆ្នាំ២០០៧។ នៅមុននេះ ឯកឧត្តមបានបំរើការងារនៅក្នុងក្រសួងយុត្តិធម៌អស់រយៈពេល១១ឆ្នាំ ព្រមទាំងជាប្រធានការិយាល័យកិច្ចការរដ្ឋប្បវេណី។ ឯកឧត្តម **យូ ប៊ុនឡេង** បានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យទីក្រុងហូជីមីញ ប្រទេសវៀតណាមក្នុងឆ្នាំ១៩៨៩។ បន្ទាប់មក ឯកឧត្តមបានបញ្ចប់ថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០០៤។ ឯកឧត្តមបានទទួលការបណ្តុះបណ្តាលផ្នែកស៊ើបអង្កេតរឿងក្តីឧក្រិដ្ឋកម្មអន្តរជាតិនៅ ទីក្រុងឡាអេ ប្រទេសហុល្លង់ និងបានទទួលសញ្ញាប័ត្រជាច្រើនផងដែរ ដូចជា សញ្ញាប័ត្រវិជ្ជាជីវៈតុលាការ វចនស័ព្ទបច្ចេកទេសច្បាប់ជាភាសាអង់គ្លេស និងប្រព័ន្ធច្បាប់និងតុលាការ។ ឯកឧត្តមជាសាស្ត្រាចារ្យផ្នែកច្បាប់ នៅសាលាភូមិន្ទរដ្ឋបាល សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ឯកឧត្តមក៏ជាសមាជិកនៃក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាសម្រាប់វិជ្ជាជីវៈតុលាការផងដែរ។

**លោកស្រីបណ្ឌិត ZHANG Binxin** គឺជាអ្នកស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិតនៅសាលាច្បាប់សាកលវិទ្យាល័យស៊ាម៉េន។ លោកស្រី បានទទួលសញ្ញាប័ត្របណ្ឌិតច្បាប់អន្តរជាតិនៅសាកលវិទ្យាល័យ Renmin ប្រទេសចិន។ ចំណាប់អារម្មណ៍ការស្រាវជ្រាវចំបងរបស់លោកស្រីគឺច្បាប់និងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ហើយលោកស្រីបានបោះពុម្ពផ្សាយសៀវភៅមួយស្តីអំពីឧក្រិដ្ឋកម្មសង្គ្រាម និងអត្ថបទជាច្រើនស្តីអំពីបញ្ហានានាទាក់ទងនីតិវិធីព្រហ្មទណ្ឌ។ ក្នុងឆ្នាំ២០០៩ លោកស្រីជាសមាជិកមួយរូបនៅក្រុមឃ្លាំមើលការជម្រះក្តីរបស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ី(AIJI) លោកស្រីបានបំរើការជាអ្នកឃ្លាំមើលការជម្រះក្តីសំណុំរឿងឌុច នៅអ.វ.ត.ក។

# ព័ត៌មានអំពីអ្នករៀបចំ

សន្និសីទនេះ ត្រូវបានរៀបចំរួមគ្នាដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) និងគណៈកម្មាធិការ ប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC):** ECCC ឬ អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ក្នុងអំឡុងរយៈពេលនោះ មានអ្នកស្លាប់ចំនួនយ៉ាងហោចណាស់១,៧ លាននាក់ ត្រូវបានគេជឿជាក់ថា ស្លាប់ដោយសារការបង្អត់អាហារ អំពើទារុណកម្ម ការសម្លាប់រង្គាល និងការបង្ខំឲ្យធ្វើការជាទំងន់។ ជាតុលាការមួយដែលបង្កើតឡើងតាមរយៈ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អ.វ.ត.ក គឺជាតុលាការកម្ពុជាបណ្ដោះអាសន្នមួយ ដោយមានការចូលរួមរបស់អន្តរជាតិ និងដែលគេជឿជាក់ថា តុលាការនេះនឹងនាំយកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ពង្រឹងនីតិរដ្ឋនៅ ក្នុងប្រទេស និងលើកស្ទួយការផ្សះផ្សារជាតិ។

**គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC):** CHRAC ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ដោយក្រុមអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងសមាគមជាច្រើន ក្នុងគោលបំណងសហការរួមគ្នា ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស, លទ្ធិប្រជាធិបតេយ្យសេរី, និងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា។ ចាប់តាំងពីការបង្កើតរបស់ខ្លួនមកសមាជិកថ្មីជាច្រើនបានចូលរួមដោយជោគជ័យជាមួយ CHRAC។ ថ្មីៗនេះ សម្ព័ន្ធអង្គការ-សមាគមនេះមានសមាជិកចំនួន២១ ហើយសមាជិកទាំងអស់ជាសមាគម អង្គាការឯករាជ្យ, មិនលំអៀង, មិនមាននិន្នាការនយោបាយ, និងមិនស្វែងរកប្រាក់ចំណេញ ដែលកំពុងប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា។

## ព័ត៌មានទំនាក់ទំនងនៃសហអ្នករៀបចំ


**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**
អាស័យដ្ឋានៈ ផ្លូវជាតិលេខ ៤, សង្កាត់ចោមចៅ, ខណ្ឌដង្កោ, ភ្នំពេញ
ទំនាក់ទំនងអ៊ីម៉ែលៈ info@eccc.gov.kh
ទូរស័ព្ទ: 023 219814 | ទូរសារ: 023 219814
គេហទំព័រ: www.eccc.gov.kh

**គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)**
អាស័យដ្ឋានៈ ផ្ទះលេខ ៩Eo ផ្លូវលេខៈ ៣៣០, ខណ្ឌចំការមន, ភ្នំពេញ
ទំនាក់ទំនងអ៊ីម៉ែលៈ chracsecretariat@yahoo.com
ទូរស័ព្ទ: 023 301 415/ 023 305 609 | ទូរសារ: 023 218 759
គេហទំព័រ: www.chrac.org

# ព័ត៌មានអំពីអ្នកផ្តល់ថវិកា និងអ្នកគាំទ្រ

គំនិតចូលរួមក្នុងការរៀបចំសន្និសីទស្តីពី គេរដំណែល ត្រូវបានចូលរួមផ្តួចផ្តើមរួមគ្នាដោយលោក Simon Meisenberg (ជាទីប្រឹក្សាច្បាប់នៃអង្គការ CIM ប្រចាំនៅសាលាដំបូងនៃអ.វ.ត.ក), លោកស្រី Michelle Staggs Kelsall (ជាមន្ត្រីផ្នែកច្បាប់របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា) និងលោកបណ្ឌិត Ignaz Stegmiller (ទីប្រឹក្សារបស់អង្គការ GIZ ប្រចាំនៅ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា)។

សន្និសីទនេះ ត្រូវបានឧបត្ថម្ភគាំទ្រថវិកាដោយស្ថាប័នសំខាន់ៗ រួមមានដូចជាៈ

## ម្ចាស់ជំនួយ

**ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ សហព័ន្ធអាល្លឺម៉ង់ (BMZ)**: BMZ គឺជាក្រសួងមួយនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។ ក្រសួងនេះត្រូវបង្កើតឡើងក្នុងឆ្នាំ ១៩៦១ ដោយបង្កើតនូវសេចក្តីណែនាំសម្រាប់ការគោលនយោបាយអភិវឌ្ឍន៍របស់ប្រទេសអាល្លឺម៉ង់។ BMZ បានផ្តល់មូលនិធិជំនួយអភិវឌ្ឍន៍ក្រៅប្រទេស តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី និងតួអង្គមិនមែនរដ្ឋជាច្រើនទៀត។ សម្រាប់ព័តមានបន្ថែម សូមអាន www.bmz.de

**ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA)**: DANIDA គឺជាអង្គការ ដាណឺម៉ាកមួយស្ថិតនៅក្នុងក្រសួងកិច្ចការបរទេស នៃប្រទេសដាណឺម៉ាកដែល បង្កើតឡើងដើម្បីផ្តល់ជួយផ្នែកមនុស្សធម៌ និងជំនួយក្នុងកិច្ចអភិវឌ្ឍទៅប្រទេសផ្សេងៗទៀត ដោយផ្តោតលើការអភិវឌ្ឍប្រទេស។ វាបានបង្កើតក្នុងឆ្នាំ ១៩៦២។

## អ្នកគាំទ្រ

**អង្គការអាល្លឺម៉ង់ដើម្បីសហប្រតិបត្តិការអន្តរជាតិ(GIZ)**: GIZ គឺជាសហគ្រាសរបស់រដ្ឋសហព័ន្ធ និងគាំទ្ររដ្ឋាភិបាលអាល្លឺម៉ង់ក្នុងការសម្រេចគោលបំណងសហប្រតិបត្តិការអន្តរជាតិ ដើម្បីឲ្យមានាការអភិវឌ្ឍប្រកបដោយចិរភាព។ សម្រាប់ព័តមានបន្ថែម សូមមើល www.giz.de

**The Centrum fur international Migration und Entwicklung (CIM):** CIM គឺអង្គការដែលជួយរៀបចំចាត់ចែងធនធានមនុស្ស សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍអាល្លឺម៉ង់។ CIM ផ្តល់នូវអ្នកជំនាញបច្ចេកទេស និងការគាំទ្រជាច្រើន។ ដើម្បីប្រតិបត្តិការរួមគ្នា CIM មានការគាំទ្រពីដៃគូដ៏រឹងមាំចំនួនពីរៈ អង្គការ GIZ និងភ្នាក់ងារកិច្ចការសហព័ន្ធអាល្លឺម៉ង់ (BA)។ សម្រាប់ព័តមានបន្ថែមសូមមើល www.cimonline.de

**សេវាសន្តិភាពសម្រាប់ជនស៊ីវិល (CPS)**: CPS គាំទ្រគម្រោងពាក់ព័ន្ធនឹង ការងារក្រោយជម្លោះ និងការកសាងសន្តិភាព។ សម្រាប់ព័តមានបន្ថែម សូមមើល www.ziviler-friedensdient.org

**ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)**: OHCHR គឺតំណាងឲ្យការប្តេជ្ញាចិត្តរបស់ពិភពលោកចំពោះឧត្តមគតិជាសាកលនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស។ វាមានអាណត្តិការងារតែមួយគត់ពីសហគមន៍អន្តរជាតិ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ OHCHR ត្រូវបានដឹកនាំដោយឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងជាផ្នែកមួយនៃលេខាធិការដ្ឋានសហប្រជាជាតិ ដែលមានការិយាល័យក្រុងហ្សឺណែវ។